វិន័យបណ្ឌិតោ ភិក្ខុ ឡ៉ាំង-ខាត់

# វប្បធម៌-អរិយធម៌ខ្មែរ-ឥណ្ឌា

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធិកសិក្សា

ព.ស. ២៥១៣ គ.ស. ១៩៧០

# ពាក្យនាំ

សៀវភៅនេះ កើតឡើងដោយមានគំនិតថា :

"កាព្យឆ័ន្ទខ្មែរ" ផ្សេងៗ តាំងពីដើមរៀងមក ទាំងសិក្សាត្រិះរិះ ពិចារណាឃើញថា "កាព្យឆ័ន្ទខ្មែរ" របស់យើង មានហើយ ពីសម័យព្រេងនាយ ។ នៅផែនដីសុវណ្ណភូមិ ប្រទេសខ្មែរ ជាប្រទេសបុរមបុរាណ មានវប្បធម៌ [illegible] ក៏ជារបស់ ស្រុកសាធ ៗ តំណាក់ចែន អង្គរធំ ឬក្រៅ សុខ-ថៃ (ឬ សុក-ថៃ) ជាបង្ហាញនូវកាព្យឆ័ន្ទខ្មែរ ។ ហេតុនោះហើយ មាន ការលាយកាព្យឆ័ន្ទលទ្ធិព្រាហ្មណ៍ និងពុទ្ធសាសនា ដែល ផ្សាយចេញមកពីប្រទេសឥណ្ឌា ។

ដូច្នេះ ដើម្បីឱ្យយល់លទ្ធិសាសនាព្រាហ្មណ៍ និងពុទ្ធ-សាសនា ត្រូវមើលប្រទេសឥណ្ឌា ជាប្រទេសទាទ្វេនគ្គា ។ ទឹកដីឥណ្ឌាដូចម្តេច បានជាគេគោរពសាសនាព្រាហ្មណ៍មុនលទ្ធិ ហិណ្ឌូព្រមទាំងពុទ្ធសាសនា ? ។ បើយើងនិយាយថា ប្រទេសកម្ពុជាជាកូនទាខ្មែរបេតង យើងក៏អាចនិយាយថា ប្រទេស ឥណ្ឌាជាកូនទាទ្វេនគ្គាដែរ គឺទឹកដីប្រទេសទាទ្វេនគ្គានេះហើយ

ដែលនាំឲ្យកើតលទ្ធិព្រាហ្មណ៍ និងពុទ្ធសាសនាឡើង ។

ខ្ញុំដើររកពាក្យពុម្ពខ្មែរ តាមទំនងនេះ ៗ ខ្ញុំបានឃើញខ្លះ ហើយប្រមូលយកមកទុកក្នុងសៀវភៅនេះ មិនមែនគ្រប់គ្រាន់ទេ នៅច្រើនណាស់ ដែលខ្ញុំប្រុងនឹងប្រមូលយកមកចងក្រងជាមួយគ្នានៅពេលតទៅមុខ ទុកសម្រាប់ការសិក្សាវប្ប-ធម៌ខ្មែរនិងរកពុម្ពខ្មែរតទៅ ៗ

ខ្ញុំសុំអរគុណយ៉ាងក្រៃលែងទុកក្នុងទីនេះផងចំពោះលោក ញូង-សឿង ដែលលោកបានជួយពិនិត្យកែតម្រូវ ដោយយកចិត្តទុកដាក់ក្នុងការបោះពុម្ពសៀវភៅនេះ ៗ

មួយទៀត ការរៀប, ការតាក់តែងដំបូង តែងមានការខ្វះ មិនសព្វគ្រប់ មិនសមរម្យ មិនពេញលេញស្រួល មិនគាប់ចិត្តអ្នកទស្សនាជន, ទាំងអស់នេះបើមាន សូមអភ័យទោស ហើយ សូមជួយបំពេញឲ្យផង ៗ ខ្ញុំសូមអរគុណជូន ទុកក្នុងទីនេះផង ៗ

ភ្នំពេញ ថ្ងៃ... ខែ... ឆ្នាំ ១៩៦៨

រៀបរៀងដោយ ... ឈិន-ទាត់

## ជំពូកទី ១

---

# ឥណ្ឌាបុរាណ

ដើមឡើយ ប្រទេសខ្មែរបានស្គាល់ប្រទេសឥណ្ឌានេះថា ស្រុកកុឡិង (កលិង្គ) ដែលជារដ្ឋមួយនៅខាងទក្ខិណាបថ សព្វថ្ងៃហៅ ឱរិស្សា (Orissa) ឬ ជម្ពូទ្វីប ឬក៏ មជ្ឈិមប្រទេស ពុំនោះទៅ មធ្យមប្រទេស តែក្នុងបច្ចុប្បន្នកាលនេះបានស្គាល់ថា "ប្រទេសឥណ្ឌា" ហើយ ។ សមញ្ញាថា "ឥណ្ឌា" នេះជានាមថ្មីការ ក្នុងប្រទេស ជាភាសាហិណ្ឌីថា "ភារត" ។ កាលពីព្រេងនាយ គេបានឲ្យនាមបញ្ញត្តិប្រទេសនេះថា "ភារត វស៌ៈ" (ភារតៈ វឞ៌), ភារត-ខណ្ឌ

បុត្តមារិកា-ខណ្ឌ តែខាងនេះ បានត្រឹមតែភូមិភាគមួយចំណែក នៃប្រទេស ដែលមានមហានទីដ៏សំខាន់ពីរគឺ សិន្ធុ និង គង្គា (Sindhu-Gangà) តែប៉ុណ្ណោះទេ ។ ឯនាមថាជម្ពូទ្វីប "កោះមានដើមជម្ពូជាគោលចារិក" នេះ ក៏ជានាមពីព្រេង ហាយដែរ តែបានដល់ប្រទេសឥណ្ឌា ដែលជាអង្គភាព (Entité) នៃភូមិសាស្ត្រប្រទេសនេះ ។

ប្រទេសឥណ្ឌានេះ មាននាមផ្សេងៗ គ្នាទៅទៀត ដូចជាភាសាអឺរ៉ុបថា "ហិណ្ឌូស្ថាន" (Hindosthen) ហើយជាភាសាហិណ្ឌី "ហិណ្ឌូស្ថាន" (Hindûsthen) នាមទាំងពីរនេះ កាលដើម គេចង់សំដៅយកតែដែនដីខាងភាគឧត្តរប៉ុណ្ណឹងទេ តែក្រោយនេះបានទៅជានាមប្រទេសឥណ្ឌាទាំងមូលហើយ ។ ពាក្យថា "ហិណ្ឌ" ជាភាសាប៉ារ្សិ (Perse) បានសេចក្ដីថា "ទាំងអស់" ជាពាក្យដែលយារក្លាយពីពាក្យដើមថា "សិន្ធុ" ដែលជាឈ្មោះមហានទី "សិន្ធុ"(ប.សំ.សិន្ធុ ១៤ន្ទូ,

សមុទ្រ) បានក្លាយតាមសូរសំឡេងភាសាបារាំងមួយទៅទៀត ជាភាសាអង់គ្លេសថា "ឥណ្ឌុស" ហើយក្លាយបន្តមួយគ្រឡប់ទៀតទៅជាក្រិកថា ៖ "ឥណ្ឌា" (India) រួចតាំងក៏ថា "ឥណ្ឌា" (India) ដែលវិលទៅជាបារាំងសែសថា "អាំងដ៍" (Inde) ។ នោះជាមូលបញ្ហា ខាងចាំងអស់នេះ ក៏នេះ[illegible] ទៅលើភូមិភាគមហានទីសិន្ធុតែមួយនោះទៀត ។ រីឯភូមិភាគមហានទីសិន្ធុនេះ គេបានស្គាល់ទូទៅហើយ ព្រោះភូមិភាគនេះ គេទុកជាទ្វារចូលទៅកាន់ប្រទេសឥណ្ឌា និងជាច្រកចេញទៅកាន់លោកខាងក្រៅផងទៀត ។ ក្នុងបច្ចុប្បន្នកាល នាមបញ្ញត្តិថា "ឥណ្ឌា" (India) នេះ មិនមែនសំដៅសេចក្ដីត្រឹមតែភូមិភាគឧត្តរ ដូចកាលដើមនោះឡើយ ស៊ីរហូតទៅដល់ប្រទេសឥណ្ឌាទាំងមូល ហើយជាតាមផ្លូវការថែមទៀតផង ៕

បើពាក្យថា ហិរណ្ណស្ថាន ឬ ហិណ្ឌូស្ថាន "ស្ថានឬប្រទេសនៃជនហិណ្ឌូ" ជាពាក្យដែលបានក្លាយមកពីពាក្យ

ឈ្មោះថា "សិន្ធុ" គឺយក ស > ហ (សប្តៈ សិន្ធវេស) ទៅជា ហប្តៈ ហិន្ទុ តាមភាសាប៉ាំស៊ី ជាឈ្មោះប្រទេសនៃជនអារយ៉ន (Aryan) ដែលមានក្រាទុក ក្នុងគម្ពីរវេទ និងគម្ពីរវេន្ទីទាទ (Vendidad) និងជារៈតាលិកា នៃអារយ៌ធម៌ពីព្រេងនាយទៀត ផង គួរតែរក្សាពាក្យដើមទុកសមដែរ គឺឲ្យទៅជាសិន្ធុស្ថាន (Sindhusthan) ស្ថាន ឬ ប្រទេសនៃជនសិន្ធុ តែការនេះជា ឥឡូវនេះ គេនិយាយតែងតែជាទុសគ្នា នាមទាំងពីរនេះ សកលលោកទទួលស្គាល់ទូទៅហើយ ។

ពួកអ្នកបរទេសទូទៅ ក៏បានស្គាល់ប្រទេសនេះយូរយារ ហើយ យល់ស្របគ្នាហៅផែនដីភាគក្រោមមហានទីសិន្ធុកាល ពីដើមនោះ ថាប្រទេសហិណ្ឌុហើយ ដូចសេចក្តីតទៅនេះ

លោកដារយុស (Darius) ហៅថា "ហិ (ណ) ទុស៊ី (Hi(n)dus), លោក ឯឡាមិត (Elamites) ហៅ ថា "ហិ - ឥនិ - ទុ - ឥស៊ី (Hi - In - du - is) លោក

ហេរូដូត (Hérodote) បានយកឈ្មោះនេះ បកប្រែប្រើថា ឈ្មោះមនុស្សថា "ឥណ្ឌូ-អ៊ី" (Indo — i), ឯលោកហ៊ានត្សាំជាតិចិនថា "អ៊ិន-ទូ" (In-tou), ឯអ្នកដំណើរចិនឯកទៀតហៅថា "ចិន-ទូ" (Chen-Tou < Sindhu) ឬក៏ "ទៀន-ជូ" (Tien-Tchou) ។ តែឈ្មោះទាំងអស់នេះ គ្រាន់តែជាសូរសព្ទ ដែលអ្នកបរទេស ហៅប្រទេសឥណ្ឌា ដោយសម្លេងផ្សេងៗ គ្នា តែប៉ុណ្ណោះទេ ។

ឯអ្នកប្រទេសឥណ្ឌាគឺជនហិណ្ឌូ ដោយកាលមុន គឺក្នុងព្រាហ្មិន "ព្រាហ្មណ៍" និងពួកជេន "អ្នកកាន់សាសនាព្រះជិនៈ" (សាកែនិគន្ថនាដបុត្រ) ហៅដែនដីឥណ្ឌា ដែលជាប្រទេសនេះ ចាប់តាំងតែពីហិមពាន្តហិមាល័យរហូតទៅដល់មហាសមុទ្រថា ភារតៈ វស៌ៈ (ភារតៈ វ៌ឞៈ) គឺប្រទេសនៃព្រះបាទភារតៈ ដែលជាព្រះកេជាមួយព្រះអង្គ មានងារល្បី-ល្បាញក្នុងគម្ពីរបុរាណៈ ។ ឯកភាពជាបាទនៃប្រទេសឥណ្ឌានេះ

ឋិតនៅក្នុងពាក្យថា ភារតៈ វស៌ៈ ឬ ប្រទេសនៃព្រះបាទភារតៈដែលជានាមមានកត់ត្រាទុកមកក្នុងគម្ពីរមហាកាវ្យៈ និងគម្ពីរបុរាណៈ ឯជនតមក បាននាមថា ភារតី សន្តតិ=ពូជពង្សនៃព្រះបាទភារតៈ ដូចសេចក្តីក្នុងគម្ពីរវិស្ណុបុរាណថា(១)

ឧត្តរំ យត្សមុទ្រស្យ ហិមាទ្រេឝ្ចៃវ ទក្សិណំ
វស៌ំ តទ្ភារតំ នាម ភារតី យត្រ សន្តតិ ។

ប្រែថា ប្រទេសដែលឋិតនៅទិសឧត្តរនៃសមុទ្រ និងទិសទក្សិណ នៃមហាបព៌តហិមាល័យ បាននាមបញ្ញត្តិថា ភារតៈ វស៌ៈ ឯជនក្នុងប្រទេសនេះ ក៏បាននាមថា ភារតី សន្តតិ=ពូជពង្សភារតីតមក ។

គម្ពីរពុទ្ធសាសនា ហៅប្រទេសឥណ្ឌានេះថា ជម្ពូទ្វីប ។ ឯរឿងព្រេងនាយ មាននិទានទុកថា ជម្ពូទ្វីបនេះជាទ្វីបមួយក្នុងទ្វីបទាំងបួន ដែលមានភ្នំសិនេរុជាមជ្ឈមណ្ឌល គឺ បុព្វ ឬ

---

១— 11 5-1

បូព៌វិទេហទ្វីប នៅទិសបូព៌ា មនុស្សមុខមូល ដូចព្រះច័ន្ទ ពេញវង់, អបរគោយាន (ក្នុងគម្ពីរខ្លះហៅអមរគោយាន) នៅ ទិសបស្ចិម មនុស្សមានមុខសំប៉ែត, ឧត្តរកុរុទ្វីប នៅទិស ឧត្តរ មនុស្សមានមុខដូចខែមួយចំហៀង ឯជម្ពូទ្វីប នៅ ទិសទក្សិណ មនុស្សមានមុខដូចព្រាយរទេះ ។ រីឯទី តាំងនៅនេះ អ្នកតារាសាស្ត្រហិណ្ឌូយល់ថា រូបរាងផែន- ទ្វីបមួយភាគធំផងគឺ មហាប្រទេសទាំងនេះ ដែលជា ៧ ទ្វីប ( ៧ ឬ ៩ ប្រទេស? ) ។ ឯជម្ពូទ្វីប ដែលជាភាគនៃផែនដីមួយ យ៉ាងធំក្នុងចំណោមទ្វីបទាំង ៧ នេះ មានសហជាតិរួមរាប់រយ គ្នាផង ។ គម្ពីរពុទ្ធសាសនា មាននិយាយដែរថា ប្រទេស ឥណ្ឌានេះ មានទ្រង់ទ្រាយដូចរទេះគោ បែរមុខរទេះទៅ ទិសទក្សិណ មានគល់រីកធំទៅខាងទិសឧត្តរ ។ គម្ពីរព្រាហ្មណ៍ និយាយថា ផ្ទៃដីប្រទេសឥណ្ឌានេះ មានទ្រង់ទ្រាយបញ្ចុំងចេញ ទៅក្រៅប្រាកដដូចស្លឹកស្រណ្តឹក ( ជាត្រីកោណ ឬ ជាអក្សរ

កើតឡើង ▲ ។ អត្ថបទសាស្ត្រឥណ្ឌាបុរាណមានសរសេរ ប្រាប់ទ្រង់ទ្រាយប្រទេសឥណ្ឌាទុកថា « ប្រទេសឥណ្ឌានេះ មានទ្រង់ទ្រាយជាជ្រុង ៤ ( ចតុរស្សស្មានសំស្មិតម៍ ) ។ គម្ពីរ បុរាណៈ អធិប្បាយពីទ្វីបនេះជារឿងប្រតិស្នូច្រើនប្រការណាស់ តែមិនយកមកធ្វើជាការបានទេ ។ គម្ពីរពុទ្ធសាសនាបញ្ជាក់ ទៀតថា ជម្ពូទ្វីបនេះជាឈ្មោះផែនដីទ្វីបក្នុងបួនចំណែក តែ ខាងត្បូងប្រទេសចិន ហើយគេបានប្រើពាក្យនេះដកមកដល់ សតវត្សរ៍ ៣ មុនគ្រិស្តសករាជ ផ្សព្វផ្សាយ ។ ជម្ពូទ្វីបលាត សន្ធឹងទៅវែងឆ្ងាយប្រមាណជាបួនម៉ឺនយោជន៍ គឺ ៤.០០០ យោជន៍ ជាសមុទ្រ, ៣.០០០ យោជន៍ ជាបព៌តហិមាល័យ ៣.០០០ យោជន៍ជាទីស្ថានមនុស្សអាស្រ័យនៅ ។

គម្ពីរវេទនិយាយថា បព៌តវៃតាឌ្យ (Vaitedliye) គឺក្នុង វិន្ធ្យាចលៈ ដែលចែកប្រទេសឥណ្ឌាជាពីរផ្នែក គឺ ភាគ ឧត្តរ ហៅថា អារ្យាវត៌ៈ ភាគទក្សិណហៅថា ទក្សិ·

ណាត្យ: (Daksinatya) ទក្ខិណាបថ ។ មហាបព៌តហិមា-
ល័យ ជាបព៌តមួយ ក្នុងជួរបព៌តទាំង ៧ ដែលជាប្រាការការ
ពារប្រទេសឥណ្ឌាខាងទិសឧត្តរ ។

ប្រទេសឥណ្ឌានេះ បើគិតពីទីតាំងរបស់ខ្លួនពិតៗ នោះ
គេចែកជា ៤ ភាគធំៗ តាំងពីបុរាណកាលមកគឺ

១– ភាគបព៌តឬប្រទេសហិមពាន្តនៅទិសឧត្តរ

ហៅថា បព៌តាស្រយិន (បព៌តាស្រយិន Parvatâçrâyin)
ដែលមានគ្រោងទុកក្នុងគម្ពីរបុរាណ: ចាប់ពីតំបន់ព្រៃស្មាប់នៃ
ទីវាលតារៃ ឬ តរាក្លៃ (Terai) ទៅដល់កំពូលមហាបព៌ត
ហិមាល័យ ព្រមទាំងទីឋានដែលមនុស្សគេស្រ័យនៅបាន
ដូចប្រទេសកស្មីរ, កង្គ្រា (Kangra) តេហ្រ៊ា (Tehri) និង
កុមាអួន (Kumâun) នេប៉ាល, សិក្ខិម (Sikkim) និង
ភូថាន (Phûthân); ជាដើម ។

២– ភាគទីវាលដ៏ធំទិសឧត្តរ ចាប់ពីតំបន់ទំនាប

ផ្ទៃស្រែចំការមាននៅតាមដងមហានទីសិន្ធុ និងស្ទឹងច្រើនជា ដៃនៃមហានទីនេះ ព្រមទាំងវាលខ្សាច់ ថារ (Thàr) ដ៏ល្ហល្ហេ នៃភូមិភាគសិន្ធុនិងរាជបុត្រស្ថានអស់នេះ រហូតទៅដល់តំបន់ មានជីជាតិនៅតាមដងមហានទីគង្គានិងទន្លេជម្នា ឬ យមុនា (Jamna/Yamuna) ព្រមទាំងមហានទីព្រហ្មបុត្រផង ។

## ៣. ភាគខ្ពង់រាបនៃប្រទេសឥណ្ឌាភាគកណ្ដាល

គិតចំពោះតែភាគខាងត្បូង និងទក្ខិណាបថ ចាប់ពីភាគខាងត្បូងនៃវាលមហានទីគង្គា ជួរភ្នំបារិបាត្រ (Paripàtra) ដ៏ធំ ទាំងភូមិភាគសំណល់ឧបទ្វីបភ្នំវិន្ធ្យាភាគបស្ចិម ភ្នំវិន្ធ្យាទាំងមូល តំបន់សហ្យាទ្រិ (Sahyadri) ឬឃាតភាគបស្ចិម និងតំបន់ មហាទ្រូះ ឬឃាតបូព៌ ។

**៤. ភាគមាត់សមុទ្រ** តាមវាលបង្កាជីវនេះហើយ ចាន្ទ្រៃគនៃវិសវត្យុណា ដែលលាតសន្ធឹងតាំងពីឃាតទៅដល់មាត់សមុទ្រ ពប់ចាប់តាំងពីកំពង់សុគស្ពូនៃនេះរកាងតាន

(Kônkàn) ព្រមទាំងឆ្នេរម៉ាលបារ (Màlabàr) និងដីសណ្ដដី មានដីជាតិនៃស្ទឹងគោទាវេរី ក្រិស្ណានិងកាវេរីផង ។

លក្ខណៈភូមិប្រទេសឥណ្ឌា ដែលទុកជាស្នាដៃធម្មជាតិ បានតាក់តែងឡើងនេះ មិនមែនស្របទៅតាមការបែងចែកនៃអ្នកភូមិសាស្ត្រ ដែលបានធ្វើទុកជាប្រពៃណីតាំងតែពីបុរាណកាលមកនោះទេ ។ ក្នុងអក្សរសាស្ត្រឥណ្ឌាបូរាណ យើងបានឃើញលោកបែងចែកភូមិភាគប្រទេសឥណ្ឌានេះ ជា ៥ ចំណែកគឺ :

## ១- មជ្ឈដ្ឋានទំនាបសិន្ធុ-គង្គា (Indo-Gangétique)

ហៅថា មធ្យទេស (មធ្យទេឝ) តាមគម្ពីរព្រាហ្មណ៍ថា លោកសន្មតតាំងពីស្ទឹងសរស្វតី (សរសុតី, សល្វតី?) ដែលហូរកាត់តាមភូមិភាគថានេស្វរ (Thànecvar) និងបេហូវ៉ា (Pèhoa) ដែលមានឈ្មោះតាំងពីបុរាណថាព្រឹថុទកៈ (Prthûdaka) ឆ្ពោះទៅកាន់ក្រុង អល្លហាបាទ (ប. បយាគ, សំ. ប្រយាគ)

ខិងក្រុងពាកណសី ។ គម្ពីរពុទ្ធសាសនាថា ចាប់ពីស្ទឹងសរស្វតីទៅភ្នំរាជមហ័ល (Rājmahal) ។

## ២– ភាគបស្ចិមនៃភូមិភាគខាងលើនេះ ហៅថា

ព្រហ្មាវត៌ ព្រហ្មសិ៌ទេស (ព្រហ្មឫ៌ទេស, Brahmarsideça) ឯភូមិភាគនៃតំបន់នេះទាំងអស់ មានទំហំប៉ុនគ្នាដែរ ហៅថា អាយាវត៌ ឬ អាយាវឋ ដែលមានស័ព្ទក្នុងវេយ្យាករណ៍នៃបតញ្ជលី ប៉ុន្តែគម្ពីរធម៌សាស្ត្របាននិយាយថាក្នុងកាលនោះ ការកំណត់ទីតាំងទាំងនេះ មានសេចក្តីខុសឆ្ងាយណាស់ ក៏ លោកប្រមូលយកទឹកដីដ៏ធំទាំងអស់ ដែលនៅចន្លោះមហាបព៌តហិមាល័យនិងមហាបព៌តវិន្ធ្យា ព្រមទាំងទីជាប់នឹងមហាសមុទ្រនិងសមុទ្រទិសបស្ចិមទៀត ។ តាមលោកព្រាសី (Prasii) ជាអ្នកប្រវត្តិសាស្ត្រនៃព្រះបាទចន្ទ្រគុប្តមហារាជ មានសេចក្តីថា :

## ៣– ភូមិភាគឧត្តរនៃមជ្ឈទេស (Madhyadeça)

ឬ ហៅជាខេត្តដែលនៅខាងជើងភូមិភាគ បេហ្វា (Pèhoa) ហៅថា "ឧត្តរបថ" (Uttaràpath) ឬ ឧទីច្យ: (Udicya) គឺ ភូមិភាគខាងជើងប្រទេសឥណ្ឌា ។

៤_ ភូមិភាគបស្ចិម ហៅថា "អបរន្ត:" (Aparànta) ឬប្រតីច្យ: (Praticya) គឺ ភូមិភាគបស្ចិមប្រទេសឥណ្ឌា ។

៥_ ភូមិភាគទក្សិណ ហៅថាទក្ខិណាបថ (Dakkhi-nepath) ឬ ដេក្កង់ ឯភូមិភាគនេះបូព៌ាដេក្កង់ នេះថា បូព៌ទេស (បូព៌ទេស) ឬ ប្រាច្យ: (Pràcya) ។

ពាក្យថា "ឧត្តរបថ" គេហៅចំពោះតែប្រទេសឥណ្ឌាភាគឧត្តរតាំងពីមួយប៉ុណ្ណោះទេ ។ ឯទក្ខិណាបថ តាមគម្ពីរបុរាណ ក៏គេហៅចំពោះតែប្រទេសឥណ្ឌាទិសខាងត្បូងភាគលើ ដែលនៅខាងទិសឧត្តរនៃស្ទឹងក្រឹស្នាតែប៉ុណ្ណឹងទេ ភូមិភាគខាងត្បូងណាទៅទៀតហៅថា "តាមិលកម" (Temila-kam) ឬតាមិលណាត (Tamilnat) "ប្រទេសតាមិល" ។

...ទេស (បូរ៌ទេត) កាលនៅពីព្រេងនាយ លោករួមបញ្ចូលគា...ន៍ទាំងគឺតែ "មជ្ឈិមប្រទេស" នុះផង គឺយក...ដែនត្រង់អន្តរវេទី (Antaravedi) ឬ ទោ - អាប (Do-ab gangétique) នៃប៉ុណ្ណោះ ។ ការចែកជា ៥ ចំណែកដូចបាននិពោលមកខាងលើនេះ តាមគម្ពីរបុរាណខ្លះ លោកបានបន្ថែមភូមិភាគដទៃ ២ ទៀតគឺ ភូមិភាគ បរិតាត្រាយ៉ទិ ឬ ប្រទេសហិមពាន្ត ឬ កំរិមាចប្រទេស ទិស់ពបខមហាបរិភាគខាងរៀតផង ។

គម្ពីរត្រៃបាលបានអាចចំណាលទុកថា ប្រទេសឥណ្ឌានេះ ចែកទៅជាភូមិភាគធំ ៦ ភាគគឺ

១- មជ្ឈិមជនបទ ឬមជ្ឈិមប្រទេស (មធ្យមទេស ជាពាក្យក្នុងទីសម្បូនជនបទ)

២- ហិមវន្តប្រទេស ឬ បរ៉ែតាត្រាយ៉ទិ

៣- ទក្ខិណបថ ឬ ទក្សិណ្យៈ

៤- ទក្ខិណាបថ ឬ ទាក្សិណាត្យៈ

៥- បុព្វន្តៈ ឬ ប្រាច្យៈ

៦- អបរន្តៈ ឬ ប្រតីច្យៈ ។

គម្ពីរមហាវគ្គ(១) មានសេចក្ដីថ្លែងថា មធ្យមជនបទ មជ្ឈិមទេស ឬ មធ្យទេស មានព្រំប្រទល់ដូចតទៅនេះគឺ

១- ទិសបូព៌ា មាននគរមួយឈ្មោះគជង្គលៈ ខាងនាយនិគមនេះ មាននិគមមួយទៀត ហៅថាមហាសាល ខាងនាយតទៅពីនិគមនេះ ហៅថា បច្ចន្តជនបទ ខាងអាយចូលមក ហៅថា មធ្យមជនបទ;

២- ទិសអាគ្នេយ៍ មានស្ទឹងមួយឈ្មោះសល្លវតី ខាងនាយស្ទឹងនេះតទៅហៅថា បច្ចន្តជនបទ ខាងអាយចូលមក ហៅថា មជ្ឈិមជនបទ;

៣- ទិសទក្សិណ មាននិគមមួយឈ្មោះថា សេត-

---

១ ចម្មក្ខន្ធកៈ ព្រះត្រៃបិដក សៀវភៅទី ៧ ទំព័រ ២០៤ ។

គណ្ឌិកៈ ទាំងខាងនិគមនេះកទៅ ហៅថា បច្ចន្តជនបទ ទាំងខាងចូលមក ហៅថា មជ្ឈិមជនបទ;

៤ ទិសបស្ចិម មានស្រុកព្រាហ្មណ៍ឈ្មោះ ថូនគ្រាម ទាំងខាងថូនគ្រាមនេះកទៅ ហៅថាបច្ចន្តជនបទ ទាំងខាងចូលមក ហៅថា មជ្ឈិមជនបទ;

៥- ទិសឧត្តរ មានភ្នំឈ្មោះឧសីរធជៈ ទាំងខាងភ្នំនេះកទៅ ហៅថា បច្ចន្តជនបទ ទាំងខាងភ្នំនេះចូលមក ហៅថា មជ្ឈិមជនបទ;

ត្រូវយល់បន្ថែមប្រទេសទិសបូព៌ា គឺត្រូវយល់ប្រទេសឥណ្ឌាទិសបូព៌ា បានលាតទៅដល់គជង្គលៈ ឬទៅដល់តំបន់បុណ្ឌ្រវទ្ធនៈ (Pundràvardhana) ។ កាលពីសម័យក្រោយមក លោកមេបញ្ចូលតំបន់វរេន្ទ្រៈ (Varendra) ទៀតផង ព្រោះតំបន់នេះគេយល់ថា ជាវិហារនៅភាគឧត្តរនៃបេង្គាល (Bengal) ។ វរេន្ទ្រៈជាមជ្ឈមណ្ឌលសំខាន់នៃការ

លក់ដូរទំនិញពាណិជ្ជកម្ម ។ ព្រំប្រទល់ទីបំផុតខាងទិសបស្ចិមនៃ
វង្គៈ (បេង្គាល) គឺវង្គរដ្ឋៈនិងមគធៈ ។ តំបន់លាឡៈ
(Làla) ឋិតនៅត្រង់ចន្លោះវង្គៈម្ខាងវង្គកលិង្គម្ខាង ។ តែក្នុង
កាលតមក វង្គៈបានដល់វង្គបេង្គាលទាំងមូល ។ ឯក្រុង
សុវណ្ណកូដ ឬ សុវណ្ណកុឌ្ឌ ក៏ជាមជ្ឈមណ្ឌលនៃការលក់ដូរ
ទំនិញពាណិជ្ជកម្មសំខាន់មួយទៀតដែរ ។ អ្នកខ្លះយល់ថា ទី
ក្រុងនេះ នៅក្នុងកាមរូបទេ ។ ប្រទេសសុហ្មៈ (Suhma)
ក្នុងសុត្តសាសនា ក៏មានសេចក្ដីដំណាលទុកថា អង្គព្រះ
សម្ពុទ្ធស្ដេចទ្រង់យាងទៅដល់ដែរ ។ ក្រុងកំពង់មាត់សមុទ្រ
ដែលមានឈ្មោះប្រាកដថា តាម្រលិត្តិ (P.Tàmelitti, S.Tàm-
ralipti) សព្វថ្ងៃនេះ ឋិតនៅត្រើយបស្ចិម នៃស្ទឹងរូបនារា-
យណៈ (Rùpanàràyana) ហៅតាម្លុក (Tàmluk) នៅ
ក្នុងតំបន់មិទ្នបុរ (Midnapur) ។ ទីក្រុងវធមានៈ គេយល់
ថាជា ក្រុងពុរឌ្វន (Burdwan) សព្វថ្ងៃនេះ ។ ជនបទ និគម

កជង្គល: ឬគៀ-ជូ-ហោះ-ទី-ឡូ នៃលោកហ៊ាន-ត្សាង(១) ជាព្រំប្រទល់ទិសបស្ចិមនៃបុរ៏ទេស (Purvadeça) តែទីនេះ ប្រហែលជានៅក្នុងតំបន់រាជមហ័ល (Ràjmahal) ទេ ។

ព្រំប្រទល់មជ្ឈិមប្រទេស ទិសទក្សិណ បានដល់ព្រំប្រទល់ប្រទេសឥណ្ឌាទិសទក្សិណ ពោលគឺមាហិស្សវតី ដែលគេសំដៅយកក្រុងមាន្ធាតា នៅតាមដងស្ទឹងនម៌ទា ឬ នម្មទា ទីនេះឬ ដែលជាសេតកណ្ណិកនិគម ? ឯតំបន់ស្ទឹងគោទាវរី និង នម៌ទាជិតនៅក្នុងទក្ខិណាបថទេ ។ ស្ទឹងគោទាវរីហូរចុះទៅកាន់សមុទ្រពង្គ័ល ក្រុងប្រតិស្ឋាន (Pratisthàn) សព្វថ្ងៃហៅប៉ៃថាន (Paithân) នៅតាមដងស្ទឹងគោទាវរី ទីនេះ គេទុកជាទីបំផុតខាងត្បូងនៃផ្លូវធំទិសទក្សិណ ដែលចេញមកពីក្រុងរាជគ្រឹះ ។ ក្រុងប្រតិស្ឋាន ឬ ប៉ៃឋាននេះ នៅជិតក្រុងថ្មីមួយឈ្មោះបញ្ចវតី ក្នុងតំបន់នាសិក (Nàsik) ។

---

1 Travals of Hiouen-Tsang, vol 44, p. 402 by Samuel Beal

ទៅតាមដងស្ទឹងគោតាវរី មានរាជាណាចក្រ ២ គឺរដ្ឋអស្សកៈ (AssaKa) រាជធានីឈ្មោះបោតនៈ (Potana) ឬពោធន្យៈ (Paubanya) និងរដ្ឋអឡ្យកៈ (Aaloka) ឬមូឡ្យកៈ (Mùlaka) រាជធានីឈ្មោះបតិដ្ឋាន (Patitthàn) តមក ឋិតនៅវិសុទ្ធគរ ក្រុងតាសប្តិទរៅវិញ ។ កំពង់ៈកាលបត្តនៈ Kolapattana) ជាក្រុងកំពង់នៅឆ្នេរៈការ៉ូម៉ង់ដែល (Coromendel Coreman-dala=ពារបណ្ដាល) ។ ឯការៈ បុក្ខៈសល ឈរសល និងសិទ្ធត្តាំងរស់នេះ ឋិតនៅប្រទេសអន្ធ្រៈ (Andhra) ។ ឯដែនដីនៃទ្រាវីឌ (Dravida) កប់យករដ្ឋចោឡ្យៈ រាជធានីឈ្មោះកាញ្ចីបុរី សព្វថ្ងៃហៅ កញ្ជីវរម (Conjeeveram) ឯរដ្ឋបាណ្ឌ្យ (Pandya) រាជធានីឈ្មោះ មធុរសុត្តបត្តនៈ សព្វថ្ងៃហៅ មធួរ (Madoura) រដ្ឋចេរៈ សព្វថ្ងៃហៅ កេរលា (Keralà) ។ រដ្ឋកលិង្គៈ (Kalinga) ជារាជាណាចក្រមួយ រាជធានីឈ្មោះ ទន្តបុរ (Dantapur) ឋិតនៅជិតតំបន់

ជីកាកូល Chicacole នៅតែសមុទ្រ ពេង្គិល ។ ក្រុងឧទ្រះ (Odra) និងក្រុងឧក្កលៈ (Utkala) ទាំង ២ នេះ ជាភាគនៃដែនដីនៃដែនឧរិស្សា (Orissà) ។ ឯប្រទេសមេកលៈ (Mekale) ជាដែនដីប្រកតីមួយ សព្វថ្ងៃគេហៅយកតាំងពី អមរកណ្ដកៈ (Amorakenteka) និងទីឋានដែលនៅជិតខាងនេះទៀតផង ។

ព្រំប្រទល់មជ្ឈិមប្រទេសពាយព្យ គឺប្រទេសឥណ្ឌាទិសបស្ចិមនិងពាយព្យ បានដល់ស្រុកព្រាហ្មណ៍មួយឈ្មោះ ពូនត្រាម តំបន់ប្រឹថុទកៈ (Prthudaka) គឺពេហូអា (Pehoa) សព្វថ្ងៃនេះ ខាងទិសឧត្តរនិងទិសបស្ចិមទល់នឹងភ្នំបព៌តហិ-មាល័យ រីទិសបស្ចិមលាតសន្ធឹងទៅដល់សមុទ្រអារ៉ាប់ ។ តំបន់ឧក្កលបថ នៅទិសឧត្តរនៃតំបន់ អបរន្តៈ ឬ ប្រទេសឥណ្ឌាទិសបស្ចិម ។ ទិសបស្ចិមនៃមជ្ឈិមជនបទ ដែលមានត្រាទុកក្នុងគម្ពីរពុទ្ធសាសនានោះ លោកក៏សំដៅយកទីឋានប្រជុំក្រុងនិងមហានទីសិន្ធុ ដែលសុទ្ធតែហូរមកពីមហាបព៌ត

ហិមាល័យ ។ ប្រទេសសំខាន់ៗ ដែលនៅក្នុងភាគនេះគឺ គន្ធារៈ កម្ពោជៈ, កុរុទេសៈ, យវនៈ, បារទៈ (Parada) សិន្ធុ-សៅវីរៈ (Sindhu-Sauvira), មទ្រៈ, កេកយៈ (Kekaya) ទរទៈ (Darada) ពព៌រៈ (Barbara=Barbare) វាល្ហិកៈ (Valhika) ឧឌ្ឌកាស្មីរៈ ។ កាស្មីរៈ (Kàçmira) ឥឡូវនេះ គឺជាកស្មីរ និងជម្មូ (Jammù) ដែលមានក្រុងស្រីនគរជារាជធានី ជិត នៅទិសបូព៌ានៃក្រុងបេសាវរ (Peshawar) និងក្រុងរាវ-ល្បិណ្ឌិ (Rewalpindi) ។ ទិហានរដ្ឋយវនៈ (Yavana) កម្ពោជៈ (Kemboja) នៅក្នុងប្រទេសអាហ្វហ្គានីស្ថាន (Afghànisthan) ។ ឯពាក្យថា សិន្ធុ ប្រហែលជាសិន្ធុ (Sind) នៅសមុទ្រគាក់ប់ ។ សៅវីរៈ (Sauvira) ជាអាណាចក្រមួយ មានក្រុងរោរុកៈ (Roruka) ជារាជធានី ។ ពព៌រៈ (Barbara) គឺពព៌រិកុម (Barbaricum) ដែលមាន

និយាយនៅក្នុងបុរិប្ល៊ុស (Pariplus) ជាក្រុងផ្សារនៃមិន្នគរ (Minnagar) នៅឯភូមិភាគសមុទ្រអេរីត្រេ (Erythrée) ។ ឧត្បលាវតី (Utpalàvati) សំដៅយក បុស្កាវតី គឺក្រុងបរ័ង្គ (Parang) និងចរស្ស៊ាដ (Charssada) នៅចម្ងាយ ១៧ ម៉ៃល៍ពីភ្លៀសានទិសកើតតាមដងស្ទឹងស្វាត (Swat) ។ មហានទីសិន្ធុ ស្ទឹងវិតម្សា (Vitamsà) វិតស្តា (Vitastà) ឬឈេលុម (Jhelum) និងស្ទឹងចន្ទ្រភាគា (Chandrabhàgà) សុទ្ធតែជាស្ទឹងសំខាន់ៗ នៅក្នុងតំបន់នេះ ។

ព្រំប្រទល់មជ្ឈិមប្រទេសទិសបស្ចិម តាមគម្ពីរពុទ្ធសាសនា បានដល់ប្រទេសឥណ្ឌាភាគទិសបស្ចិម និងទិសឧត្តរ នៃមជ្ឈិមជនបទ ឯទិសទក្សិណនៃទក្ខិណាបថ បានដល់ឆ្នេរសមុទ្រឥណ្ឌាទិសបស្ចិម មានរដ្ឋគោណៈនិងរដ្ឋកស្ត្រៈ រដ្ឋទេវសកា សុរាស្ត្រៈ ភ្រឹគុកច្ឆៈ (Bhṛgukaccha) អានត៌ៈ និងអព៌ុទៈ (Anarta et Arbuda) ទាំងអស់នេះ សុទ្ធតែជាប្រទេសដែល

នៅទិសបស្ចិមប្រទេសឥណ្ឌា ។ ភ្ឫគុកច្ឆ គឺព្រូច (Broach) សព្វថ្ងៃនេះ ដែលនៅក្នុងតំបន់កឋិយាវ៉ាដ (Kathiawad) ។ សព្វថ្ងៃនេះ រដ្ឋសុរាស្ត្រ: កប់យកកឋិយាវ៉ាដនិងភាគរដ្ឋគុជរាតទៀតខ្លះផង ។ ឣាសិក គឺតំបន់ឣាសិកសព្វថ្ងៃនេះ ដែលនៅតាមដងស្ទឹងគោធាវរី ទិសពាយព្យក្រុងបុំបៃយ ប្រមាណជា ៣៥ ម៉ៃល៍ ។ សោវីរ: សំដៅយកតំបន់ ឯដេរ (Eder) ដែលជាតំបន់មួយនៅក្នុងរដ្ឋគុជរាត ក្រុងក្បាលឈូងកំបៃយ (Combay) ។

ឯប្រទេសទាំង ១៦ ដែលមានក្រោមក ក្នុងគម្ពីរពុទ្ធសាសនា គឺរដ្ឋកាសី មានក្រុងពារាណសីជារាជធានី រដ្ឋកោសល (សំ.កោសល) មានក្រុងសាវត្ថី (សំ.ស្រាវស្តី) និងសាកេតជារាជធានី រដ្ឋអង្គ: មានក្រុងចម្បាជារាជធានី សព្វថ្ងៃនៅក្នុងតំបន់ភគល្បូរ (Bhagalpur) និងម៉ុងឃីរ (Manghyr) រដ្ឋមគធ: សព្វថ្ងៃហៅពិហារ (Vihara) មានក្រុងរាជគ្រឹះជារាជ-

ធានី (ក្រុងបុរាណហៅគិរិព្វជៈ ប្រែថា "គ្រោល" បាន សេចក្តីថា មានបព៌តជាប្រាការព័ទ្ធជុំវិញ) ឥឡូវ ដែនពិហារ ខេះ មានក្រុងបត្នៈ (បាដលីបុត្រ) ជារាជធានី នៅក្នុងតំបន់ គយា ដែនវជ្ជីមានក្រុងវេសាលីជារាជធានី សព្វថ្ងៃហៅពាសរហ៍ (Basarh) នៅក្នុងតំបន់មុសាហ្វាបុរ (Muzaffapur) ដែន មល្លៈ មានក្រុងកុសិនារា ឬកុសិនគរជារាជធានី សព្វថ្ងៃហៅ កាសា (Kasia) និងបាវាបុរិ (Pàvàpuri) ដែនចេតី ឬ ចេតីនៅតាមដងស្ទឹងជមុនា (យមុនា) ហើយលាតទៅដល់រាជា-ណាចក្រកុរុទៀត, ដែនវំសៈ (vamsa) ឬវត្សៈ (Vatsa) មាន ក្រុងកោសម្ពី (សំ-កៅសម្ពី) ជារាជធានី សព្វថ្ងៃហៅកោសម្ពនៅ ជិតក្រុងអល្លាហាបាទ ដែនកុរុ (កុរុក្សេត្រ ឬថានេស្វរ (Thaneçvar) នោះមានស្ទឹងសរស្វតី (Sarasvati) ដែលនៅទិសឧត្តរ និង ស្ទឹងទ្រឹឞទ្វតី (Drsadvati) ដែលនៅទិសទក្សិណ ដែនបញ្ចាល បាន ២ គឺ ឧត្តរបញ្ចាល មានក្រុងអហិច្ឆត្រ (Ahichatra)

ជារាជធានី សព្វថ្ងៃហៅថា រាមនគរ (Rāmnagar) នៅក្នុងតំបន់បារៃលី (Bāreilly) ។ ឯទក្ខិណបញ្ចាល មានក្រុងកាម្បិល្យៈ (Kāmpilya) ជារាជធានី សព្វថ្ងៃ ហៅកម្បិល (Kāmpil) នៅក្នុងតំបន់ហ្វារុខាបាទ (Farru-khabād) ដែលនៅក្នុងឧត្តរប្រទេស រដ្ឋមត្ស្យៈ (Matsya) នៅក្នុងតំបន់ជ័យបុរ (Jaipur) រដ្ឋសុរសេនៈ មានក្រុងមថុរា ជារាជធានី រដ្ឋអស្សកៈ ឬអស្មកៈ (Açmaka) មានក្រុងពោតនៈ ឬពោតលី ជារាជធានី រដ្ឋអវន្តិ សព្វថ្ងៃនៅក្នុងតំបន់មាល្វា (Malva) និងនិមរ (Nimar) ព្រមទាំងចំណែកដែលនៅជិតមធ្យមប្រទេសផង, រដ្ឋគន្ធារៈ នៅក្នុងតំបន់បេសាវរនិងក្រុងរ៉ាវល្ពិណ្ឌីក្នុងវិហារបញ្ចាប; ឯរដ្ឋកម្ពោជៈ ជាប្រទេសមួយដែលនៅចុងបំផុត ខាងទិសឧត្តរនៃប្រទេសឥណ្ឌា ។

# ឥណ្ឌាបច្ចុប្បន្ន

រូបសណ្ឋានដែនដីប្រទេសឥណ្ឌា សណ្ឋានទ្រង់ទ្រាយទាំងមូលនៃប្រទេសឥណ្ឌា គឺជាចតុកោណបុមមិនស្មើ ឬជាត្រីកោណពីរផ្សំគ្នាបុបគស្មើ មានខ្សែកក្កដនិវត្តន៍ (Tropique du cancer) ជាអក្សរឆ្លុះគោលសមប្បមាណ (Axe de symétrie) និងជ្រុងរួមគ្នា (Côté commun) ។ ផ្ទៃទិសបស្ចិមធំជាងផ្ទៃទិសបូព៌ ។ សមប្បមាណនៃផ្ទៃទាំងមូល មិនសមរម្យគ្នាល្អទេ ព្រោះត្រីកោណទិសឧត្តរ ដែលជាប់ទៅខាងខ្ពង់រាបប៉ាមៀរ (Pamir) ទើបទាំងទិស

បសុបក្សី ។ ឯភាគឧត្តរនៃខេត្ត ព្រះវិហារនកលធំ គេបានកើតមានដីរក្សាចុះគន្លូល បកតទៅឆ្ងាយពីកំពង់សមុទ្រ ជាទីឋានដែលកើតមានព្រឹត្តិការណ៍ផ្សេង ៗ នៃប្រវត្តិសាស្ត្រ ជាទីប្រាសាទ ... ធំៗ ដែលជាកេរ្តិ៍ដំណែលរបស់អ្នកស្រែចំការ ដែលជាបូរាណ គឺវិហារនេះហើយដែលជាកំណើតសាសនាព្រាហ្មណ៍ ជាសាសនាដែលមិនមានអ្នកណាម្នាក់ដឹងសោះថា កើតឡើងពីអង្កាល ជាកេរ្តិ៍ដំណែលអ្នកដែលនៅខាងជើងប្រទេសនេះ មាន...ចាប់កើតតាមគតិកាលណា ៗ សព្វថ្ងៃនេះ ភូមិភាគនេះនៅជាជនបទស្រ័យនៅឆ្ងាយខ្លាំងណាស់ ។

ដែនដីភ្នំខាងឧបទ្វីប (ទក្ខិណាបថ) ជាភូមិភាគមាត់សមុទ្រ មានព្រៃព្រោងធំសម្បូរណាស់ តែស្រូវមិនសូវមាន ឈូងដែកសម្រាប់ជាទីអាស្រ័យនៅនៃនាវាទេ ត្រង់នេះ មានតែថ្ម ត្រង់កោះ មានទឹកកក់ពេក ត្រង់នោះទៀត កៀនកោះមានភក់ច្រើន ឯនោះតទៅទៀតជាទីមិនមានអនាម័យសោះ ។

ដូច្នេះ កាព្យ៍ធំមិនសូវកើតមានឡើងក្នុងភាពគ្មានអាក់សម្បុរ នេះទេ មានតែកាព្យ៍ធំគួរជាទីនិយមជាងគេបង្អស់ និង កាព្យ៍ធំតាមបែប ទោះជាប្រើប៉ុន្មានខែនៅឆ្នាំទៀតក៏ ៗ ហើយ លើកលែង ក្នុងប្រយោគភាពខាងក្រៅនេះចេញ ហើយយើង ពិចារណាមើលខ្លួនប្រកបនិងប្រកបបទ (Antithèse) ត្រូវប្រើជំនួសគ្នា នៃប្រទេសក្រិកនិងឥណ្ឌានោះវិញ ឲ្យយើងថាមានការដូចគ្នា ដូចមេឃនិងដី ឃើញថា យើងមិនអាចយល់ពីជាប្រាកដគ្រប់ គេតែងការស្រេច ៗ ហើយចុះ ប្រទេសក្រិក មានទឹកដីហេល្លាដ (Hellade) ក្នុង ដំណើរសម្បូរលាយតែក ៗ មានភ្នំ មានកៀនកោះ គឺនៅទីវាលនេះហើយដែលកើតមនុស្សមួយបែប កើតកាព្យ៍ធំមួយបែបគឺបែបក្រិក ឯទីវាលដែលកើតមនុស្ស មួយបែបនិងកាព្យ៍ធំមួយបែបទៀតនោះ គឺប្រទេសឥណ្ឌា បុរាណនោះឯង ។

ការមើលទឹកដីឥណ្ឌា មិនមែនតែឲ្យយើងយល់នូវបុរាណ

សុភាសិតក្រិកដែលថា "មិនមានអ្វីដែលលើសនេះទៀត" នោះ ទុកជាការត្រូវពិតមែនខាង ៗ ធម្មជាតិវិតសឹតក្កា កាចរឹងប៉ឹង ណាស់ មិនងាយនឹងបត់បែនទៅតាមចិត្តមនុស្សណាឡើយ ភ្នំស្ងួតថ្មក្រាស់ប្រមាណពាន់ហត្ថ ៗ មើលចុះ ខ្ពង់ខ្ពស់កាត់ពពក ដី ហេការសុទ្ធសាប មេឃមើលទៅ ដៃត្រឹមក្រោមស្លាក ការចាក់ផ្លាស់គ្នាក្រោមក្រៃ ៗ មើលចុះ! មហាបព៌តខ្ពង់ខ្ពស់ គគ្រឹកគគ្រេង ព្រោះផ្គររន្ទះលាន់ឮពេញគ្រប់ទិសទី ជាតិ មនុស្សនេះធ្វើបាប ធ្វើបាន ដែលភាពមានវណ្ណៈទៀត ៗ ការ ចាក់ផ្លូវស្រួលគ្រប់គ្នាមើលទៅធម្មជាតិវិតក្កៈនេះមិន ព្រមឲ្យគេធ្វើបានងាយនោះទេ វិស្វករនិពន្ធនានាបាន ស្វែងរកផ្លូវពុំទាន់បានពេញចិត្តនៅឡើយ ឯវិស្វករ ផ្សេងគ្នាស្រឡះ ស្វែងរកលក្ខណៈល្អ បុគ្គលឲ្យប្រសើរស្រ- ឡះពិតៗ ។ ទីហ៊ានទៅរកបញ្ចប់ផ្លូវដែក មិន មានផ្លូវមិនមានមធ្យោបាយ តាំងពីក្រុងគាគឡាហ៊រ (Lahore)

រហូតទៅដល់ក្រុងភគ័លបុរ (Bhagalpur) មានចម្ងាយប្រមាណ ជា ១.៥០០ គ.ម. ។ នៅក្នុងភូមិភាគទាំងនេះ ប្រជាជន រាប់លានរស់នៅ ហើយអាស្រ័យនៅក្នុងទឹកដីនេះ តែបើ មើលទៅជីតទៅទៀតឃើញថា ប្រជាជនទាំងឡាយនេះ នៅ ក្រោមភាពលំបាក ខ្វះខាតទាល់ខាតនៅឡើយ ។ ក្រុងធំៗ របស់ឥណ្ឌា ស្ទើរតែសុទ្ធតែមានប្រវត្តិ ជាក្រុងមិនធម្មតា គឺប្រ ទីងមានក្រុងពិតថ្មីដូចជាក្រុងពារាណសីដែលជិតទៅគោរព រហូតតាំងពីព្រេងនាយមកនោះហើយ មានច្រើនតែក្រុងបែប ក្រុងដែលគេបោះបង់ចោលកប់នៅកណ្ដាលព្រៃ ម្ដាយ ក៏ដល់ឥឡូវ នេះមិនទាន់នៅថា "ក្រុងខ្មោច" ក៏សុំជាប់ ដូចក្រុង ហើយក្រោយ ក្រុងការគណ្ឌជាដើម គឺទៅអនាគត មើលទៅក្រុង ទាំងនេះគង់មិនរួចពីបាត់បង់ដូចជាក្រុងបុរាណដែរ ។ មនុស្ស ជាតិដែលនៅក្នុងប្រទេសឥណ្ឌាទាំងមូល ក៏ហាក់ដូចជាវិញ្ញាណ ហៃលស់នៅតែក្នុងមហាផែនដីដ៏ធំ ទង់ល្បីល្បាញនេះដែរ ។

សភាពទឹកដី- ប្រទេសឥណ្ឌា គួរនឹងចាត់ទុកជាប្រទេស

ឧបទ្វីប ។ ភាគទក្សិណនៃផលនេះហៅថា ដេកាន់ (ទ.ទក្កណ

ក.តក្កណ, ប.ទក្ខិណ, ស.ទក្សិណ "ត្បូង, ទិសត្បូង") ជា

ទីហ៊ានខ្ពង់រាប គាល់ពីបុរាណនោះ ជាទ្វីបគន្ធវ៉ា (Gandwana)

ជាប់ភ្ជាប់គ្នាទៅដល់កោះ អូស្ត្រាលី (Australie) កោះ

ម៉ាដាហ្គាស្ការ (Madagascar) និងទ្វីបអាហ្វ្រិក (Afrique) ។

ខ្ពង់រាបពីបុរាណនេះ ជាភាគដ៏រឹងក្រាស់ ជាថ្មខ្លាំង

សម្បើមណាស់ ហេតុសម្បូរគ្រះហើយក្រោយនៅខាងទិសទក្ខិណ,

លុះចំណេរមកកាលមក ក៏កាលឡើយនោះ ភាគដែលខ្ពង់ខ្ពស់

រណ្ដាក់ខ្ពស់ទៀតនៅភាគខាងជើង ហាបត៌ាកហិមាល័យ

និងសមុទ្រ ក៏កាលគមក ល្បប់ដៃលោយទឹកខាងកើតទៅ

យកទៅនាំឲ្យបានជាកោក កើតបាននៅជាដីទំនាបល្អណា-

គង្គាមានកម្រាស់ ៥.០០០ ម៉ែត្រ នៅក្រុងភាកណាសី ល្បប់ដី

ទៅភាគលិចលុកណៅ (Lékhnau) មានកម្រាស់ ៤០០០ ម៉ែត្រ ជាដីមានជីជាតិល្អណាស់ ។ ឯសមុទ្រគឺឆ្ងាយឃ្លាតនៅខាងទិសបស្ចិម ហើយទុកទីវាលដើមមួយទៀតជាក្រឡដីលិចទឹកដែលឈ្មោះជា ទន្លេ "សណ្ដ-ព្រហ្ម" (តាមលោក Poscoe) ដែលចេញពីភូមិភាគអាសាម (Asam) ទៅដល់ភូមិភាគបញ្ចាប គឺពីខាងកើតទៅបស្ចិម កប់យកផ្ទៃដីមហានទីគង្គាទាំងមូលនិងភាគមហានទីស៊ិន្ធុខាងក្រោមផង ។

ចុះហេតុម្ដេចក៏បានជាមហានទីគង្គា ប្ដូរតាមផ្លូវទឹកបច្ចុប្បន្ននេះវិញ ? មកដោយមានការស្រុតផែនដីចាស់ ដូចជាការស្រុតដីនៅចន្លោះភ្នំគារ៉ូ (Gâro) និងភ្នំរាជមហាល់ជាដើមដែរ ហើយជាចំបងមហានទីនេះ គឺស៊ិន្ធុ គង្គា ជា ២ កំណាត់ មួយផ្នែកបានជាមហានទីគង្គា មួយចំណែកទៀតបានជាមហានទីព្រហ្មបុត្រ ។ ឯស្ទឹងសរស្វតីសព្វថ្ងៃនេះជាស្ទឹងតូច តាមគម្ពីរវេទ ជាស្ទឹងមួយធំណាស់ដែរ ព្រោះគេ

បានឃើញជ្រលងនៅតាមភ្នំខ្ពង់ ត្រង់ភូមិភាគប៉ារ (Thar) ដែលជាស្ពានប្រទ្បាយស្ពារមេទឹកមួយធំ ហូរចេញមកពីតំបន់ ស៊ីមឡា (Simla) តម្រង់ទៅភាគក្រោមនៃមហានទីសិន្ធុ ។

ផែនដីភ្នំដែលហៅថា "ទួប កោះ" នេះ ដូចជានាំឲ្យយល់ថា កាលដើមជាដីកោះ គឺដីដែលមានទឹកព័ទ្ធជុំវិញ ជាជាទួបកោះនេះសមដែរ ។ បើយើងអោយពិនិត្យពិច័យយើងនឹងឃើញថា ភាគដីភ្នំខាងភូមិភាគទក្សិណជាខ្ពង់រាប នៃភាគដីដែលនៅតាមជ្រលងឥណ្ឌូ-គង្គា គឺតាមជ្រលងមហានទីសិន្ធុខាងបស្ចិម តទៅទៀតទៅដល់ទិសឧត្តរ និងជ្រលងមហានទីគង្គា ដែលនៅខាងទិសបូព៌ា ជាដីរាបទាំងអស់ កាលដំបូងណាព្រៃខាយ ទំនងជាឈូងសមុទ្រដែលព័ទ្ធជុំវិញខ្ពង់រាប គឺភូមិភាគទក្សិណនេះឯង ។ កាលពីអតីតកាល គឺកាលដែលភូមិភាគទក្សិណនៅជាកោះនៅឡើយ ជនានុជននៅកោះ កាលនោះ មើលពីកោះខ្លួនគាត់លំហសមុទ្រដែល

ពឹងស៊ីវិញនៅខាងវិសុទ្ធ ហើយក្រៀមក្រំព្រួយខ្ទុំម៉ៃមហាបតិ
ហោះបាត្ត ដែលក្រោយមកក្រោយទទួលស្គាល់ផុត
ចាំងពីក្រោយ ស៊ីព្រះពាក្យ ជាហេតុនាំក្រុងក្រុមភក្តិ
ក៏ទុកបានហៅឈ្មោះហើយថា "ហនុមាន" ឯរូបភាពទក្សិណា
ជាជីតាទួទ ក្រោយមកទទួលថា "ហនុមាននរលោក" ។
ហេតុនេះហើយ បានជាលោកហៅផែនដី ក្នុងទិសនេះ ដែល
មានសត្វក្របីពេលយកនឹងហៅថា "ស្វាវិជ" ? ។

រឿងព្រេងខ្មែរ មានដំណាលថាបុរាណ ផែនដីក្នុង
នេះជាតម្បូង ក្នុងមហាជាហៅនគរាស (ហិមាល័យ ?)
បើតនៅចំកណ្តាលព្រៃភ្នំ មានភ្នំប្រាំក្បាល ៗ សក្ក-
សិទ្ធ ៧ នោះត្រូវនៅវិញ ទូរពីឥស្សរិយបានមកទុកនេះ ព្រោះ
ទឹកសមុទ្រងាកនេះ ជាទឹកផ្កាសារស ក្រុមយក្សបាត់នៅ
សុទ្ធតែលិចបាត់ទៅអស់ សូម្បីតែភ្នំប្រាំប្រហែលមួយក៏
លិចបាត់ទៅដែរ មានតែព្រៃគេមានបុណ្យទេ ហើយហៅបាន

អាចធ្វើទៅបាន បើមិនទៅទៀត តែងតែជិះសត្វ[illegible] ដូចគ្រុឌជាដើម ហើយហោះនាំធ្វើយកទៅ ៗ រឿងព្រេងខ្មែរនេះ យើងមិនអួតការថាជាសេចក្ដីពិតទេ តែយើងទុកជាគន្លឹះមួយដែរ គ្រាន់នឹងក្រាលមើលសេចក្ដីពិតថាដូចម្ដេច ៗ

អាកាសធាតុ– ដែនដីក្ដៅដល់ម្ល៉ោះ រ៉ូវ ក៏ប្លែកគ្នាដែរ អាកាសធាតុមានប្រែបែប លក្ខណៈការរស់នៅប្លែកគ្នា ប្រមាណ ខ្សែរអក្សរផ្សេងៗ គ្នា ភាសាផ្សេងៗគ្នាដល់ ៩៤៥ ភាសា មហាភាសាធំៗរបស់នេះ គឺភាសាចំនួន ១៤ គឺ ហិណ្ឌី, តេគ្លិ, យកបី, គុជរាថី, បញ្ចាប់; កាស្មីរ, សិន្ធូ, ឧរិយា, តាមីល, មលយាឡំ, តេលូគូ, កន្នរ; គោណ្ឌា, គោលរ ៗ បើដើរកាត់ប្រទេសក្ដៅ ចាំដូចពីឧណ្ហភូមិ (Fournaise) នៃខិត្ត (Tropique) នៅតែក្នុងប្រទេសតែមួយនេះ យើងនឹងបានប្រទះអាកាសធាតុគ្រប់បែប គឺតាំងតែពីអាកាសធាតុបែបផ្ទះទឹកក្ដៅ (Bain de vapeur) នៃតំបន់ខ្សែអេក្វាទ័រ (Equateur)

ហេតុដល់អាកាសធាតុត្រជាក់បែបទឹកកក "ហ៊ីម ក៏ត្រជាក់" (F.frimas) ដែលជាទីឋានទឹកកកខ្ទប់នៃខ្ទង់ប៉ូលកណ្ដាល ។ ប៉ុន្តែប្រទេសនេះ មិនសូវមានខ្យល់ប្រែតាម(១) (Mousson) ដែលទុកជាខ្សែជីវិត គឺជាប្រភពនាំឲ្យមានការរស់នៅទេ ។ រយៈកណ្ដាល (Latitude( នៃប្រទេសនេះជាទីឋាននៅសារក្រោះ (Arido) ទីឋានខ្វះធម្មជាតិ ជាទីឋានដ៏សម្បើម ហើយបើក នៅជិតមហាបពតពោមតាន្ត ទីឋាននេះគេហៅថាស្រែយាលភី សីតុណ្ហភាពណាស់ មិនសមបើកស្រ័យនៅបានទេ ប៉ុន្តែមាន ខ្យល់មិនទៀងទាត់ក្រោមប្រទេសបានជួយឲ្យអាកាសក្ដៅនេះត្រឡប់ ទៅជាអាកាសត្រជាក់ស្រួលបន្តិចវិញ ។ ប្រទេសណាដែល យើងថា មិនសូវមានខ្យល់ប្រែតាមនេះ បានធ្វើឲ្យយើងដឹង កល់ត្រូវ គឺតាំងពីបុរាណមកទល់នឹងថ្ងៃនេះ ។ ក្លិមាតុន ប្រទេសកាតាប្រែន ដោយពិសេស ភាគខាងជើងតុ

---

១ គួរប្រែថា "ខ្យល់រដូវវស្សា" ព្រោះពាក្យ Mousson មានការ អធិប្បាយ ប្រែថា "ភ្លៀង" ។

ក្នុងសិសិររដូវ (វិច្ឆិកា-មីនា) សុទ្ធតែជារដូវរាំង ហើយដាច់
ស្រយាលពីសីតុណ្ហភាពពេកណាស់ ។ បន្ទាប់ពីការត្បៀងនៃខែ
ខែតុលាកទៅ ព្រៃព្រឹក្សលតាជាតិស្វិតស្រពោនក្លាយ គំណ-
ជាតិក្រៀមក្រញង់អស់ ខ្យល់ស្ងួតថែម សូម្បីតែពុនស្គរពុន
ក្របកកំផុយរបៀលរលីងស៊ែរ ពេលយប់ រាត្រីស្ងាត់ត្រជាក់
ស្រេប អាកាសស្រួលណាស់ ដោយកាំរស្មីព្រះអាទិត្យខ្លាំង
ហួស ពេលថ្ងៃ ព្រះអាទិត្យចាលរស្មីបកខ្លាំងពេក មិនបាន
អ្វីបាំងសោះតែមិនរងះថែនដែរ មនុស្សក៏មិនរលាយដូចក្រមួន
ដែរ ហើយមានខ្យល់បក់មករហើយរំភើយត្រសៀក ជាខ្យល់
ស្ងួតដែលបក់មកពីទ្វីបនៃអាស៊ីភាគកណ្ដាល ។ សីតុណ្ហភាព
មធ្យមក្នុងខែមករា ចំនួន១៣អង្សានៅក្រុងមូលតាន (Multàn) ១៨
អង្សានៅកាលកុត្តា (៦៦-៣៤), ៦០អង្សានៅបង់គ្លួរ (Banga-
lùr) (៩៦-១៧) ។ ពេលសន្និយារាត្រី សីតុណ្ហភាពធ្លាក់ចុះ
មកត្រឹម ។ សូម្បីតែត្រង់វិហាររដែលនៅក្រោមទីវគ្គន (Tropique)

សូម្បីតែនៅខាងការទក្សិណផុត គឺមានសភាពប្រហែលគ្នាដែរ គេត្រូវដុតចង្ក្រានភ្លើងអាំងទើបនៅបាន ។ នៅទីហាខឡា-ហ័រ (Lahore) ឬក៏កកហើយ, នៅបញ្ញាមទន្លេកដប្រែស្អាត សីតុណ្ហភាព ចុះមកដល់ ៥ អង្សា ។ រដូវនេះ ហៅថារដូវហេមន្ត (សំ.ហិម. Lat.Hiems. F.frimas, A.frost) តាំងពីពាក់កណ្ដាលខែវិច្ឆិកា ទៅដល់ពាក់កណ្ដាលខែមករា ។ រដូវ "សិសិរ" (សំ.សិសិរ "ត្រជាក់", F. froidure, A.cold) តាំងពីពាក់កណ្ដាលខែមករា ទៅដល់ពាក់កណ្ដាលខែមីនា ។

អ្នកសីតភីត រីករាយសប្បាយចិត្តណាស់ កាលណាបើនិតរដូវត្រជាក់ល្អមកដល់ ម្ល៉ោះហើយៈចះនៃរង្វង់តាំងមើលស្រុកនេះបីមានៈភ្លៀងធ្លាក់មួយមេឬពីរមេនៅក្នុងខែកុម្ភៈ ធម្មជាតិហាក់ដូចជារីកស្រស់ត្រកាលបើ ព្រោះដីស្ងួតមែកក្រហែងនោះបានទទួលសើមបន្តិច ៗ ស្រូវខេរដូវមិនបានៈជួសទឹកដើតជាតិឲ្យនៅតែខៀវស្រងាត់ទេ មើលទៅមេឃឃើញខ្ពស់ខៀវស្រឡះ

ក្តៅជានិច្ច ឯសន្ធឹកៈឈើដែលស្គោកក្រៀមក្រញ៉ង់ ដោយ កំដៅព្រះអាទិត្យនេះ ក៏ជ្រុះចុះអស់ នៅតែដើមជ្រើង សត្វពាហនៈស្គមឃើញតែឆ្អឹងជំនីរគឹង ឱនក្បាលចុះស្រង់ក្លិនដី ដែលបែកក្រហែងក្រៀមក្រោះល្អោល្អើដាច់កន្ទុយក្អែក ដោយទឹកប៉ុនស្រមូតស្រក់ម្ចុះគួរឲ្យគេអាណិតក្រៃលែង មានតែបុប្ផាតែមួយប៉ុណ្ណោះទេ ដែលហ៊ានចេញបុប្ផយកតែក្តុះស្គាយទៅដំងឹងគុម្ពឈើ ធ្លាក់ហើយក្រៀមក្រពើង ហើយបញ្ចេញពណ៌ក្រហមបញ្ចូល ស្រស់ញញឹម ទោលក្នុងក្រអូបប្លុយល្អបក្រឡុប់គន្ធពីដោរ ប៉ុនគួរឲ្យពេបពិលរមិលមើល ដូចជាបង្កប់អ្នកទេសចរដាក្រោមបើ បើហៅទេសភាពបែបនេះតែមួយមាត់ឲ្យថា គួរនិទានយយថា "សម្រស់ទេសភាពកក់ក្ដៅ" (ដើមគ្នា Butea frondosa, Hi, dhàk ឬ palàç «Flame of forest») ។

តបក, សត្ថុណ្ហភាពនេះតែទៀនកល់ថ្ងៃ ខ្យល់ក្តៅដួច

នេះ មកប៉ះលើខ្នងស្ទើរខ្សាច់ នាពេលត្រជាក់ ក៏ស្ទើរតែត្រាំ
មិនបាន ស្ទើរតែទៅលើកពេលហាល ក៏មិនមានខ្យល់រះហើយ
រាំងបរសារដែរ ។ នៅខែមេសា មានការដំបរវេគមួយ
បែបគ្របសង្កត់ចូលទៅតាំងបន្ទុសត្រាំងសត្វ តាំងរស់គ្នាទាំងអស់
ខ្ញុំគិតថ្មីដែលថាជាខ្ញុំ គិតឱ្យតែធ្វើបុន្ទត្រូវញ្ញូលឈប់នេះក្នុងដុត
ស្រុកខ្នះទៅតែប៉ុណ្ណោះ ។ នៅកណ្ដាលកល ឧណ្ហាក្រ
ឡើងដល់ ៤៥ ទៅ ៤៣ អង្សា ក្ដៅលើសពីកំដៅក្នុងខ្លួន
មនុស្សគឺ ៥ ទៅដល់ ៨ អង្សា ។ ឧណ្ហភាពគាបឡើង
រហូតដល់ ៥ អង្សាក្នុងម្លប់ មិនមែននៅតែតាមដងមហា-
នទីសិន្ធុដូចនៅក្រុងជេកោបាបាដ (Jacobabad) ក្រុងមូលតាន
(Multàn) ឬ ម៉ុងតោមេរី (Mongomery) ប៉ុណ្ណោះទេ ស្ទើរ
នៅក្រុងជោតបុរ (Jotpur) នៅរាជបុត្រស្ថាន ឬក្រុងអគ្រា
ដែលនៅតាមដងទន្លេជម្នា (យមុនា) ក៏ដោយ ស្ទើរតែក្ដៅ
ដូចគ្នាដែរ មិនមែនអស់ហើយទេ នៅមានខ្យល់ព្យុះខ្សាច់តាម

ទៀត ព្រោះហើយអាកាសធាតុផែនដីគាសពេញទាំងផ្ទៃទតាលើយ
ចេញមកតាំងពីរយើយ មើលទៅមុខគួរឲ្យតក់ស្លុតក្រៃកន្លង ។
ដោយអាកាសធាតុក្ដៅពេកនេះ សត្វកើតក្លាយជាតិផ្ទុះ
អស់ពពីនេះជាមនុស្សសត្វ ហាក់ដូចជាសេះខ្យល់ដកដង្ហើម ។
ប្រសិនបើជាខ្យល់ក្ដៅអាប គឺសត្វជ្រូកមិនបានយ៉ាង មើលទៅ
ប្រហែលជាសេះពីតដន្លុំតាំងអស់គ្នាមិនខាន ប្រែសេចក្ដីថា
មិនបានខ្យល់ក្ដៅអាប (សត្វជ្រូក) មិនមានជីវិតទេ ; មាន
តែក្រកើតប្រូប៊ូស្បូតាំងមនុស្សតាំងសត្វពីក ព្រោះដកឥតសល់ស្ង្រើយ
ទៀយ នេះជាអាកាសធាតុរបស់ស្នាក្រៅប្រវត្តិសត្វ ។

វិស្សាននៈទី– តំណវត្តនេះ ប្រវត្តិប្រដាប់ស្ដីអាកាស
នេះតែក្រុងផ្លាស់ប្ដូរ ។ ប្រវត្តិសត្វ ដោយពិសេស
នៅភាគកាតនេះ ស្រួសឹងជាវីហានដែលមានសម្ពាធភាព
តែងតែអាញយកខ្យល់ពីសមុទ្រ, ដលវែងឆ្ងាយទៅហើយ
ទើបបានខ្យល់ខ្យល់ផ្លាស់ប្ដូរ ខ្យល់ត្រូវបកមកពីវិសទិវាវិញ

ឯភាគ "មេឃទូត" ចិតះទៅក្តោប់ត្រដូចសន្ទិម ។ ទៅលើដី
ដែលគេហៅថាចេះនេះ ចំណុចទឹកភ្លៀងចិតះទៅខ្លាំងក្រៃលែង
ដើម្បីប្រមូលភាពញញឹមកគាប់ទៅផ្ទះអោយឱ្យភ្លាក់ដាក់ភ្លៀងធាប់ៗ
ផ្ទះគេៈគឺជាផ្លូវខ្យល់ចូកទាម (ស្លឹកខ្ចី) ខ្យល់ច្រកទាម
កាលដែលបកៈធារ មានកាកាផ្ទួចជាក្រោធខ្លាំងណាស់
គឺពពកជាទៅសំ ដែលហោះហើរចេញពីមហាសមុទ្រឥណ្ឌា
មកនោះ មកដូចជាគល់វ៉ាត(១)ដែលលុកចូលទៅក្នុងសមុទ្រហ្ម
ឈយ ហើយធ្លាក់ចុះទៅលើដីឥណ្ឌា ដូចគេដាក់ទឹកទៅក្នុង
ធ្លាក់ ។ ក្រុមជំនិតខ្យល់ក្តៅ ការសាកុប្រាប់ថាហេតុការណ៍
នៃបាតុភូតនេះជាទិញ ហើយតាមរយៈក្រៅខ្យល់ដែលបក់
ទៅរិះបចុកទៀតផង ។ ខ្យល់ចូកទាមនេះចាប់ផ្តើមពីថ្ងៃ
ទី ៣ មិថុនា នៅឆ្នេរសមុទ្រមឡាបារ (Malàbar) ថ្ងៃទី ៥
នៅកុំបៃយ៍, ថ្ងៃទី ១៥ នៅកដមុគ្រស្លាមទងនៅភក្តីការ

---

១ - ក្នុងរ មានពិភពក់នាថា ភ្លៀងធ្លាក់ចុះមក ដូចញហយាក្រៅឯកន័ត

ថ្ងៃទី ២៥ នៅអគ្រះ, ថ្ងៃទី ៣០ នៅបញ្ចប ។ ពេលនោះ ហើយដែលដុំពពកត្រូវបែកជាដុំតបនោរ និងនេះ ព្យុះក្រូង ក្តាំងខ្លាំងមហិមាដូចហែកមេឃ គ្រេងគ្រាំ ៗ ហើយគ្រហឹម គ្លុលព្យុះទៅវិញឆ្ងាយមុខគួរគត់ស្លុតក្រៃលែង ៗ នេះគឺជា ធាតុគួរគាប់សរសើរគត្តាស ជាការគម្រាមខ្លាំងឥតគណនានៃ គណៈមហាគយមហាមេឃនៃពិភពលោក ដែលចំពោះអក្សរសាស្ត្រ អណ្ដាធាតុពណ៌នាទុកថា លោកនេះទុកដូចជា "រថជាវិការ នៃដំដុត" សេចក្តីពណ៌នានេះ ត្រូវគ្រប់ពេលាខ្ញុំកាលធាតុ-គួរ សមតាមសេចក្តីពិតបំផុតមុខគួរឱ្យកោតស្ញើចក្រៃលែង ៗ

ទឹកភ្លៀងធ្លាក់ចុះម៉ែកដូចគេចាក់ទឹកដូច្នេះ សីតុណ្ហភាព កំចុះក្តាម យ៉ាងយប្យម មកនៅត្រឹម ៧ ឬ ៨ អង្សា ។ ភ្លៀង ធ្លាក់មកនេះ ខ្លាំងមហិមា ធូនកាល ៦៤ ហ៊ុន ឬក៏ ៤៥ ម៉ោង ធ្លាក់មកច្រើនបំផុតលើហួកធាងជាឯកទេស: ក្នុងពិភពលោក ស្ថានីយពិនិត្យភ្លៀងនៅចេរាពុញ្ជី (Charàpunji = Ceràpunji)

នៅក្នុងរដ្ឋអាសាម (Asam) បានឃើញថា មានទឹកភ្លៀង ទំ ០៣,៦ ក្នុង២៤ ម៉ោង ឬ ២២ម៉ី ៩០៧ ក្នុង១ឆ្នាំ គិតជា មធ្យម ក្នុងមួយឆ្នាំ ទំ៣៧ ៗ ភ្លៀងធា ហើយធ្លាក់ មកអស់កាលយូរថ្ងៃ បានគេកំណត់ហៅថា "មូសុន" "រដូវភ្លៀង" ឯអ្នកដើរសមុទ្រជាតិអារ៉ាប់ហៅថា មោស៊ិម (mousim) ប្រែថា "រដូវភ្លៀង" ដែលបារាំងយកភាសានេះ មកធ្វើជា (mousson) សំ.វប៉, ប. វស្ស, ប្រែថា "ភ្លៀង" ៗ ទាន់ដើមរដូវភ្លៀងនេះមកដល់ខែកក្កដា ជារដូវគ្រីឞ្ម (grismo) (ប. គិម្ហ) ប្រែថា រដូវក្តៅ ៗ រដូវភ្លៀងនេះហើយ ដែលធ្វើឲមនុស្សជាតិឲ្យភ្ញាក់ ឲ្យមានជីវិតរស់ឡើងវិញ សត្វ ទ្វិបាទចតុប្បាទ ផ្ទុះរលាស់ស្លាប ហិចហើរត្រៀលឆ្លាត់ អ្វីទាំងអស់ ឡើងខៀវស្រស់បំព្រង ដូចជាហេតុអស្ចារ្យ មួយកើតឡើង ឯព្រៃព្រឹក្សលតាជាតិ ផុះលូតលាស់ សន្ធឹកថ្មីខៀវខ្ចីរវក់ ងើបឡើងយ៉ាងអង់អាច ប៉ុចពន្លកចេញ

ផ្នែកលោកលោកហើង ៗ

ស្រុកខ្មែរនេះ បានជួយបន្ទរប្រទេស ឲ្យរួចផុតពីទុក្ខវេទនា៖ គ្រប់ភូមិភាគណាដែលទឹកជំនន់មិនឡើងហួសប្រមាណពេក កៃទៅតេក្ដិល ទឹកជំនន់ខ្លាំងឡើងលិចភូមិភាគច្រើនក្នុង តបនាគបនដាច់ ហើយពេលគ្រូនញ៉ាក់ទិនពេលកាលត្បាកញ៉ាំញ៉ូវទៅ ៗ ទៅភាយតើងទេ ទៃមហាបតិភហោបពាក្ក ទឹកភ្លៀងដែលធ្លាក់មកខ្លាំង បានព្រោះជំឲ្យកើតទៅជាគ្រោះជ្រលងជងរូវ រស់រណាមទឹកខ្លាំង នាំឲ្យកើតជាសឹបទិនសំរុយ ៗ ទឹកភ្លៀងនេះ ធ្លាក់មកមិនស្មើគាសព្វទីកន្លែងទេ ខ្យល់ប្រកដោម, កង់ស្សាខេផ្ទៃ, បក់មកត្រូវខាងទក្ខិណាបថភាគបស្ចិម និងភូមិភាគទៅថណ្ដាយតាមមហាបពិតហោមពាក្ក ភូមិភាគបញ្ញាបមិនស្សូវមានទេ ភូមិភាគខ្លះនៃទក្ខិណាបថកម្មជមានដែរ ដូចនៅតាមឆ្នេរសមុទ្រវិសបូតិអាស៊ី ឯនៅឆ្នេរកោរកាមដែល (ហោរមណ្ឌល) មានខ្យល់

ប្រកបដោយស្បើយណាស់ ទាល់តែមកដល់ខែតុលា វិច្ឆិកា ទើប មានខ្យល់ប្រកបដោយ គឺខ្យល់បក់ច្រាសវិលមកវិញ ៗ ហេតុ ដូច្នេះ ក្នុងកូបិកាតនេះ គេនៅតែដាំតែដំណាំស្រាល ៗ ដាំតែ ២ ឬ ៣ ខែបានផល ដូចពោត ២ ខែ ក្តីស្រូវខ្លះ ៣ ខែជាដើម ហើយគេរើដាំទៀត តែដាំបានតែ ៣ ដងទេ ហើយប្រើជលប្រទាន (Irrigation) ដូចបឹង ៗ ឯស្ទឹងធំ ឃ្លាតពីគ្នាឆ្ងាយណាស់ យូរ ៗ មានមួយ ឯថ្លុកបឹងស្រះ តូច ៗ ក្នុងសរទរដូវ (សំ.ឥរវ) ចាប់ពីពាក់កណ្តាលខែ សីហា ទៅពាក់កណ្តាលខែវិច្ឆិកា រដូវនេះ ធាតុអាកាសស្មើ គឺត្រជាក់ល្មម សន្លឹកឈើខៀវស្រងាត់ មើលទៅទេសភាព ស្រស់បំព្រង គួរពេចពិលរមិលរមល បានជាពួកអ្នកកវីឥណ្ឌា សរសើរធម្មជាតិច្រើនប្រការណាស់ ក្នុងកាលនេះ គេតែង ប្រញាប់ប្រញាល់ធ្វើកិច្ចការសព្វចំពូក ឲ្យហើយស្រឡះទៅ ហើយក្នុងរដូវនេះ ព្រះចន្ទបញ្ចេញពន្លឺត្រជាក់ស្រៃតែតដ៏ភ្លឺ

ត្រចះត្រចង់គ្រប់រាត្រី ជួយផ្តល់ឲនោរម្យរីករាយសប្បាយ ដល់ប្រជាជន មិនគួរនឹងមានការធុញណាយឡើយ ។

អ្នកស្រុកបានយល់ច្បាស់ខួបនៃពេញរដូវ ក្នុងមួយឆ្នាំៗ យ៉ាងច្បាស់ច្បាយណាស់ ៗ គេយកពាក្យថា "វស្ស=ភ្លៀង" មកធ្វើជាឈ្មោះ "ឆ្នាំ (១)" ព្រោះគេយល់ថា ការរស់នៅរបស់គេត្រឹមតែ ៤ ខែ គឺខែដែលមានទឹកភ្លៀងធ្លាក់មកជាកំណត់ ត្រជាក់ស្រួល ផ្ទុយនឹងរដូវក្តៅ ៧ ខែ ដែលមានសុទ្ធតែក្តៅហួតហែង ហើយគ្រប់គ្នាចាំប្រាំងម្ចាប់ខ្លួនឲ្យបៀមទៅ តាមសភាពវិកល ដែលមានគេជាឧកាសមុខគួរឲ្យធុញណាយ នេះពេលរាត្រី គ្រប់តែរដូវ ថ្ងៃណាដូចថ្ងៃណា បើទុកជាគ្រប់វណ្ណកាលវេលា ហួសប្រមាណពេក ជាងគ្រប់វណ្ណអាកាសក៏ដោយ គេក៏សុំអត់ទ្រាំទៅបាន ៗ គ្រប់ប្រទេស ដែលមានខ្យល់ត្រជាក់ខ្លាំង ប្រទេសស្លាក្ខាជាប្រទេសដែល

១– ធ. ហិត្លេ អាៈពាក្យ គន្ធ: ថា ផងមើ តាំងចាំទុ. ថា ..ឆ្នាំ.. ។

មានរបៀបដូវគួរឲ្យសិក្សាច្រើនជាងគេបំផុត ។

ធាតុភាពនៃភូមិភាគប្រទេសឥណ្ឌា រីឯដី ឥណ្ឌាដ៏ធំ ដែលមានអាកាសធាតុខុសៗនិងភាពផ្សេងៗ ពីគ្នាខ្លះ មានសហាយោគ (combinaison) ច្រើនបែបណាស់ គឺមាននានាភាពផ្សេងគ្នាខ្លះ មានភាពលាំគ្នាខ្លះ ហើយមិនសូវមានឯកភាពដូចប្រទេសដទៃទេ ក្នុងប្រទេសតែមួយនេះ មានសុបិភការ (Assortiment) នៃភូមិភាគមិនដូចគ្នាសោះ មិនមែនដោយហេតុតែប្រទេសនេះ មានលក្ខណៈ៣ ផ្នែក គឺមហាបព៌តហិមាល័យនៅទិសឧត្តរ ទំនាបវាលហិណ្ឌូស្ថាន និងខ្ពង់រាបនៅទក្ខិណាបថទេ ប៉ុន្តែដោយហេតុតែក្នុងភូមិភាគនីមួយៗនោះ មានលក្ខណៈផ្សេងៗពីគ្នាទៅទៀត ។

មហាបព៌តហិមាល័យ – មហាបព៌តហិមាល័យជាជាប់ផ្ទៃដីដ៏ធំមហិមានៃមហាប្រឹថពី សណ្ឋិតបណ្ដោយគ្នាទ្រវែង ក្រោយដូចធ្នូប្រវែង ២.០០០គ.ម. កម្រាស់ពី ២៥០គ.ម.ទៅ

៣០០គ.ម. ជាជួរបព៌តធំសម្បើមអស្ចារ្យនៅក្នុងពិភពលោក ។ ដើមគេ, គឺជួរភ្នំដែលលយដូចជាដៃលៀនចេញមកប្រមាណ ជា ១.០០០ម. ឈ្មោះថាស៊ីវ៉ាលក្ខ (çivàlakh) ឬ ឧបគិរី មានរូបបញ្ឈរស់លាស់លេចចេញមកកាន់ទីវាល ។ តពីជួរភ្នំមកខាងក្រោម មានទីចំនោមចង្អូរណៈយឈ្មោះថា ដូន (Dùn, សំ. ទ្រោណៈ ប្រែថា "ស្នូក") កន្លែងឈ្មាន ជាទីឋានប្បែកមួល្អ ព្រោះមានមេទឹកហូរបាក់មក ដូចជាភូមិភាគដេរ.ដូន (Derha Dùn) ដែលមានកំពស់ ៦៩០ម. ជាដើម ។ តទៅខាងខាងលើ មានភ្នំមួយចោតគ្រេន គឺភ្នំមសូរី (Masùri) កំពស់ ២.២០០ម. ជាជួរភ្នំទីមួយ ឬទីពីរហៅថា អនុហិមាល័យក៏បាន តែអ្នកស្រុកគេតែងហៅថា "ភ្នំក្រៅ" ហើយមានទីចំនោមទៀត ទីងថាជាវាលក៏បាន ដូចជាទីវាលនៅក្នុងប្រទេសនេបាល់ជាដើម ទើបដល់មហាបព៌តហិមាល័យ ។ ជួរបព៌តហិមាល័យនេះ លេចអណ្ដែតខ្ពស់ឡើងត្រដែត ជាប់

ប្រទាក់គ្នាជិត កំពូលស្រួចច្រូងច្រាង គេចូលទៅមិនបាន ទេ អ្នកស្រុកហៅថា "កុំភ្នំ" ។ មហាបព៌ត ដែលមាន ហិមៈជាប់និរន្ដរមានកម្រាស់វែងកកក់បំផុតផ្ទុះ សមគួរនឹង បានឈ្មោះថា "ហិមាល័យ" ឬ "ហិមវន្ដបព៌ត" ពិត ប្រាកដ ។ មហាបព៌តដែលមានកំពូលខ្ពស់ទាំងអស់ថិតនៅ ត្រង់មជ្ឈបណ្ដាល ដែលមានកន្លែងជួបគ្នា ជួរមហាបព៌តកេរ៉េ- រស្មិ (គោរីសង្ក) ដែលជាប់នៅមហាបព៌តកញ្ចនជង្ឃា គោលគិរី, គេហៅបប៊ូម ទៅជិតប្រភពមហានទីគង្គានី មហា- បព៌តមន្ទរទៀត, នៅត្រង់កែងមហានទីសិន្ធុមានកំពូលមួយហៅនង្គ បព៌ត, នៅឆ្ងាយពីជួរបព៌តទាំងនេះ ជាខ្ទង់កប ប្រទេសទីបេត៍ ដែលជាប្រភពមហានទីសិន្ធុ និងសត្លុជ (Satlaj) និង មហានទីព្រហ្មបុត្រ, គេហៅទៀត ជាដៃមហាបព៌តហិមាល័យ កំពស់ពី ៧.០០០ម. ទៅ ៨.០០០ម. ជាមហាបព៌តដែល លេបខ្ពង់កបទីបេត៍ដែលមានកំពស់ត្រឹមតែ ៤.០០០ម. គឺបព៌ត

សង្ការ (Zankar) ឡាដក្ខ (Ladakh) គារគោរ័ម និងជួរបព៌ត៤ ទៀតដែលមាននាមថា "កៃលាស" ។ មហាបព៌តកៃលាសនេះ មានកំពស់ ៦.០៩៤ម ឋិតនៅក្នុងភូមិភាគឡាដក្ខ ត្រង់ចំណុច ៨១° ទិសបូព៌ គឺជាតួមហាបព៌ត "កៃលាស" ដែលមាននាមល្បីល្បាញបំផុត នៅក្នុងអក្សរសាស្ត្រឥណ្ឌា មានស្រះមួយទៀត មាននាមល្បីល្បាញដូចគ្នាដែរ គឺស្រះ "មានសារោវរ" (អនោតត្ត ឬអនវតប្ត?) ទីហ៊ានស្រះនេះ ហើយដែលពួកព្រាហ្មណ៍ហិណ្ឌូទុកជាទោលិកា (Berceau) នៃបុព្វបុរសហិណ្ឌូ ៗ តាមជំនឿ ពួកព្រាហ្មណ៍ហិណ្ឌូតែងតែទៅធ្វើធម៌យាត្រាទីនេះ ហើយលះបង់ជីវិតនៅមាត់ស្រះស័ក្តិសិទ្ធិដើម្បីរួចដោយជឿ មានទេសភាពមុខគួរឲ្យមានទុក្ខជួន ក្រៃលែងព្រោះតាំងបំពេញតែចំពោះបុព្វបុរសគឺ "បិត្ត" រាល់ឆ្នាំៗ

**ទីបៀងហោមវត្តប្រទេស** ជួរមហាបព៌តហិមាល័យជាមហាប្រាការដ៏សម្បើមអស្ចារ្យ ប្រកបេញចូលគាត់មហាបព៌ត

នេះមានតិចណាស់ ហើយសុទ្ធតែខ្ពស់ដល់ទៅ ៣.៤០០ ម, ទៅ ៤.៧០០ម. ។ ឯជំរាលទិសខាងត្បូងនៃមហាបព៌ត មានភាពទីទៃៗគ្នា មើលទៅឃើញច្បាស់ ត្រង់ភាគកណ្តាល និងខាងទិសបូព៌ ជួរភ្នំធំៗនេះ មានទំនាបរាបស្រ័យនៅតិចពេក ដូចប្រទេសភូថាន (Bhùthàn) និងសិក្កិម (Sikkim) ។ ឯភាគខាងបស្ចិម មានទីរាបស្រ័យនៅបាទបព៌ត ដូចប្រទេសនេប៉ាលនិងកស្មីរ ។ ភាគទិសខាងត្បូងនៃជួរភ្នំហេមបព៌ត មានវស្សទឹកច្រើន គាំទ្រព្រឹក្សជាតិដុះលូតលាស់ទូទៅ ។ នៅជាយទីវាល បណ្តោយតាមព្រំប្រទល់ប្រទេសនេប៉ាល មានទំនាបមួយដែលគេហៅជា តារ៉ៃ Tàrài, (បាលិ: Tàr) «សើម» ជាទំនាបភក់ជ្រាំបកខ្លាច់ បំពុំបំប៉ាច់ ឥតមានអនាម័យទេ ហើយជាតំបន់ព្រៃធំញាត់ស្បាតបរិបូណ៌ដោយសត្វសាហាវដូចខ្លាជាដើម ទីនេះមានតែដំរីទេដែលជាពាហនៈអាចបុកទម្លុះកាត់មហាសាគរព្រៃនេះបាន ។ គេទៅ

មានតែដីក្រួសរវៀនស្ងួត តែបព៌តសិកលក្ខ ជាដីដុះស្មៅតែ ដើមសាលព្រឹក្ស នៅទីទំនាបអនុបព៌តនេះ មានដី“ដុន” (D0n) មានសភាពដូចជាដីតាកស៊ីដែរ ដុះស្មៅតែរុក្ខាលតាជាតិទៀត ស្រស់បំព្រងដូចបុប្ផផ្កា ឈើធំៗ និងលតាជាតិ ៗ ទីខ្ពស់ តទៅទៀត ដុះស្មៅតែរុក្ខជាតិកែកេបដូចដើមសេន (Chêne) នូយ៉េ (Noyer) ប៊ូឡូ (Bouleaux) ដ៏មានដើមស្រោប ដោយស្លែក្រាស់ ឯដើមអាព្រីកូ (Apricotier) និងដើម ប៉េសេ (Pêcher) គឺសម្បូណ៌ណាស់ដែរ ឯផ្លែវាបានជា ចំណីពេហារនៃខ្លាឃ្មុំ ៗ ទីខ្ពស់ពី ២.០០០ម តទៅទៀតមាន ដើមម៉ាញ៉ូលីយ៉ា (Magnolia) ផ្កាពណ៌ស ឬក្រហម ព្រាល, ដើមកូនីហ្វែរ (Conifère) ដើមសេនទៀត (Chêne vert) ទីខ្ពស់ទៅទៀត មានដើម រ៉ូដូដង់ដ្រុង (Rhododendron) ដើមធំៗ ប៉ុនដើមណូយ៉េ តែរដូវក្ដៅ គន់នៅល្អមើលណាស់ ៗ

ភូមិភាគទិសបស្ចិម មានភាពផ្សេងពីគ្នាបន្តិច ព្រោះឧទិន្នភាពមានចំនួនអាស្រ័យទៅបានស្រួល អាកាសធាតុល្មម មានវាលផុះស្មៅសម្រាប់សត្វពាហនៈល្អចំណាប់ ៗ ប្រទេសកស្មីរធំទូលាយហើយរាបស្មើល្អ សម្បូណ៌ស្មៅសម្រាប់សត្វពាហនៈ គឺជាប្រទេសស្វីស មួយផ្សេងទៀត ការអា-ស្រ័យនៅគួរឲ្យរីករាយសប្បាយណាស់ អាកាសល្អដូចនៅទ្វីបអឺរ៉ុប មានស្ទឹង មានបឹង មានដើមដេអូដារ (Déodar) ដើមប៉ោម ៗ ក្នុងបច្ចុប្បន្នកាលនេះ មានដំណាំផលព្រឹក្សាចំរើនថែមទៀត ៗ ភាគឧត្តរប្រទេសកស្មីរជិតទៅភ្នំការ៉ាកូរ៉ាំ (Kàrakoram) មានភ្នំជាវិហានអាស្រ័យនៅបានដែរ គឺវិហានហ៊ុនសា (Hunzà) ដែលជាប្រទេសនៃពួកផនភុរុសស្តិ (Burusehasti) មានចំនួនទឹកអាបៈថ្មីស្របការបាន ហើយក្នុងសិរីសិរផ្លូវជាទីរក្សាផ្កាអាព្រីកូ (Abricotier) ទៀត ៗ ភូមិភាគនេះ ជាប្រកបញ្ចេញទៅកាន់អាស៊ីភាគលើបាន គឺប្រក

នេះហើយដែលប្រទេសកស្មីរធ្វើការទាក់ទងជាមួយបរទេស ។

ភាគបស្ចិមតទៅទៀត ជាទីឋានព្រំសីមាប្រទេសឥរង់ ហើយបព៌តដែលជាផ្នត់មហាប្រឹថពីប្រែសភាពទៅផ្សេងទៀតគឺ បព៌តការាកោរ៉ម ជាប់តទៅបព៌តហិណ្ឌូគូស (Hindukuss) ដែលមានកំពស់ដល់ទៅ ៧.៣៥០ម. ជាទីឋានជំរាលចេញ ទៅតាមហាបព៌តហិមពាន្ត មានកំហួយនៃបរៈទៅប្រទេសឥណ្ឌា តែកំរនេះ មិនសូវជាខ្ពស់ប៉ុន្មានពេកទេ ដោយខ្លះមានច្រក ពីរបីចូលទៅមកបាន ច្រកសំខាន់គឺច្រកខៃបារ (Khaibar) ដែលជាទ្វារបច្ចុប្បន្ននៃប្រទេសឥណ្ឌា បន្ទាប់ពីច្រកនេះទៅ មានកំវ៉ាស៊ីរីស្ថាន (Wazirithàn) និងកំសុលៃម៉ាន (Sulemàn = Sulaimàn) មានកំពស់ ៣.០០០ម ។ នៅខាងទក្សិណច្រក បោឡាន (Bolàn) មានទីឋានមួយធំ សណ្ឋានដូចផ្ចិតបើក គឺប្រទេសពលូចិស្ថាន (Balûcisthàn) ។

បព៌តទាំងនេះ ជាកំពែងមួយដ៏វែងតែស្គមកំព្រឹន ជា

រនាំងបាំងខ្យល់ព្រៃភ្នំ តំបន់នេះក្តៅហែងអន្ទ ក្នុងខែ ឧសភា-មិថុនា កំដៅកំដៅឡើងដល់ ៥២ អង្សា នៅក្រុង ជាកោបាបាត (Jacobabad) តំបន់នេះហើយដែលនាំឲ្យ មានការកំណើតខ្យល់ទៅប្រទេសអ៊ីរ៉ង់ (Iran) ហើយឲ្យប្រែ ក្លាយទៅជាសភាពនៃប្រទេសប៉ាឡេស្ទីន (Palestine) វិញ ។ ទីហ្នឹងនេះ ក្រខ្វក់ណាស់ ដល់ ទៅនៃគុលសម្ព័ន្ធមួយក្រុម ដែលមានចិត្តរបិនរឹងរូស ហើយចូលចិត្តតែច្បាំង ។ ភាគ កណ្ដាលខាងកាតខ្ទុក្ត នៃភូមិភាគនេះ គឺជាប្រទេសកាប៊ុល (Kabul) កាលពីព្រេងនាយជាល់ទៅនៃគុលសម្ព័ន្ធនេះ មុន កាលដែលពួកនេះចូលទៅដល់ប្រទេសឥណ្ឌា ។

ជលសីមាមហាធទឹសិត្ថ ភូមិភាគមហានទីសិន្ធុនេះ មិនមែនជាភូមិភាគមានអាកាសល្អម ឬក៏ជាកំណើត ដែលជា ហេតុនាំឲ្យអ្នកកតញ្ញាក មានចិត្តចង់ចូលទៅប្រទេសឥណ្ឌាទេ ឬមិនជាមានហេតុដទៃទៀតក៏មិនមែនដែរ ។ អ្នកពិចារណា

រឿងនេះ បានត្រិះរិះរកគំនិតដើមនៃជនដែលចង់ចូលទៅ ថា តើហេតុដូចម្ដេចបានជាគេចង់ទៅកាន់ទីវាលបញ្ញាបនេះ គេថា អ្នកកតក្យាតដែលធ្លាប់តែនៅក្នុងទីវាលស្មៅគគ្រដើមឈើ កាលបើឃើញទីវាលបញ្ញាប ក៏នឹកស្មានថាខ្លួនអាចនឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានស្រួលក្នុងទីនេះ ព្រោះមានស្មឹង មានវាលស្មៅសម្រាប់សត្វពាហនៈ មានអាហារគោចរបរិបូណ៌ ៗ គេនៅតែទទួចចង់ដឹងទៀតថា ដូចម្ដេចបានជាអ្នកកតក្យាត ដែលចេះធាក់កាព្រោះ ហើយចេះដើរសេះតូកនេះ មើលឃើញទីវាលដែលមានស្មឹងជាដើមនេះ ថាជាទីវាលស្រួលសម្រាប់ខ្លួនទៅវិញ? អ្នកដើកេបគេយល់ថា ទីវាលនេះឥតជាការ បនគួរនឹងចង់នៅឡើយ ៗ

មហាគម៌សិទ្ធ- កាលវាល្ងបណ្ដោយតាមផ្លូវបត់តហេមពាន្តនោះ សិទ្ធហ្លួនទាំងណាស់ តែលុះចុះមកដល់ពាក់កណ្ដាល ត្រង់បត់ក្លុកដូចកែងដៃ ក៏បែកចេញជាផលមគ្គក្លូចៗ ច្រើន ផ្លូវដើមរបស់ខ្លួនគាត់យកនាមថា «សិទ្ធ» ឯដៃ

ខ្ទន ៥ទៀត គាត់យកនាមថា បញ្ចនទ ឬបញ្ចាប (បញ្ច+អាប?) «ស្ទឹងប្រាំ» គមក ប្រមូលគ្នាតែមួយ ហូរចាក់ទៅលើកសេទ្រាច់ មានពោះស្ទឹងមិនទៀង ពិភាក់ទេ គទៅបេះតែស្រមុកបទៅទៀត ។ ក្នុងបុកណាសម័យ គឺសម័យផែលកេយ៍គម៌ កំពុងបម្រើនខ្ពង់ខ្ពស់ មានអ្នកប្រាជ្ញខាងពាកសាស្ត្រ បានបង់ស្ទឹងទាំងនេះ មុកគឺស្ទឹងឈេលម (Jhelam) ចនាប (Canàb) រាវី (Ràvi) សត្លូជ (Satlaj) មិងព្យាស (Byàs) ដើម្បីបញ្ចូលទឹកទៅកាន់វិកលបញ្ជាមកាគទិសបូព៌ ធ្វើទីនេះឲ្យទៅជាដីមានជីជាតិប្រសើរ ធ្វើផលស្រូវឲ្យបានបរិបូណ៌ តែក្នុងកាលគមក ផ្លូវទឹកនេះវិនាសបាត់បង់ទៅវិញ ។ ទីឋានផែលនៅឆ្ងាយពីផ្លូវទឹក ដោយពិសេសគឺកាគខាងត្បូងស្ទឹងសត្លូជ ជាវាលកហានហៅថា «ថារ» (Thar) មានសុទ្ធតែវាលខ្សាច់ធំពេញក្ដៅអនេកអនន្ត ទ័ណ្ឌដោយវាលស្មៅគតដើមឈើនៃរុក្ខជាតិក្រស្ថាន ។

**មហានទីគង្គា**— មហានទីគង្គា «មាតា គង្គា» គាត់

យកប្រភពទឹកនៅទីឋានដែលមានកំពស់ ៤.២០០ម. នាជើង
បព៌តហេមពាន្ត ជាទីឋានធម៌យាត្រាដ៏ល្បីល្បាញ មាននាម
ប្រាកដថា «គោមុខ=មាត់គោ» ។ តាមផ្លូវទឹកហូរចុះមក
មានដងវៀចច្រើនណាស់ មករួមគ្នា ទើបបានទៅជាមេទឹកធំ
ហើយលួនតាមអនុបព៌តហេមពាន្ត រវាងដែកទឹកដីបព៌តសិវាលក្ខ
(civalakh) ទីបំផុត មកដល់ទីឋានឫស៊ីកេស (ក្បាលឫស៊ី)
ទើបចេញមកកាន់ទីវាលនៅក្រុង «ហរិទ្វារ» (ទ្វារព្រះវិស្ណូ) ។
រីឯហាបទីនេះ កាលចូលមកដល់ទីវាលហើយ គឺបិតនៅលើ
កំពស់ផ្ទៃសមុទ្រ ៣១១ម. ហើយរីកធំឡើងទៀត ហូរសន្សឹម
ស្រួលអស់រយៈចម្ងាយ ២.៤០០គ.ម. ទើបទៅចូលកាន់មហា
សមុទ្រឥណ្ឌា ។ ពាក្យថា «មាតា គង្គា» ជាវិស្សុតនាម ជាមេ
ទឹកធំមួយក្នុងពិភពលោក បណ្ដោយ ៣.០០០គ.ម. ទូជាន័យហា
នទីសិន្ធុបន្តិច តែមានទឹកច្រើនជាង ល្បឿនហូរថេរវេគ ក្នុង
វស្សរដូវ ទឹកឡើងខ្លាំង ដោយមានទឹកកកដែលរលាយ

ទៅលើកំពូលភ្នំហេមពាន្តហូរចូលមកជៀជាមួយផង ៗ វិស័យ
មហានទីនេះ មានទំហំធំណាស់ ចំនួនជាងមួយលានគ.ម.២ ។
សព្វថ្ងៃនេះ រដ្ឋាភិបាលឥណ្ឌា បានសាងទំនប់ទឹកស្កាត់ច្រើន
កន្លែងរួមទាំងអស់ប្រវែង ១៦.០០០គ.ម. មានព្រែកជីកវែងជាង
គេប្រវែង៨០០.គ.ម.ជាហេតុនាំឲ្យខ្សែទឹកហូរខ្សោយទៅវិញ។
ដៃស្ដាំដ៏ធំនៃមហានទីនេះ គឺទន្លេជម្នា (Jomnà = Yemunà)
ទន្លេជម្នានេះ មានដៃដទៃទៀតច្រើនហូរមកប្រសព្វដូចស្ទឹង
ចំបាល (Combal) និងស្ទឹងបេតវ៉ា (Betva) ជាដើម នាំឲ្យ
មានទឹកច្រើនទៀត ហើយហូរបណ្ដោយតាមគ្នាប្រមាណជា
១.៣០០.គ.ម. ទើបវិលទៅប្រសព្វមហានទីគង្គាវិញ នៅ
ក្រុងប្រយាគ (Preyâg) ឬអល្លាហាបាទ (ក្រុងព្រះអល្លាហ៍
សព្វថ្ងៃនេះ ៗ ទីឋានដែលនៅចន្លោះមហានទីគង្គានិងទន្លេ
ជម្នានេះ មាននាមប្រាកដថា «ទោ អាព» (ទោ+អាប ?)
«ទឹក=ពីរ» ដែលគេទុកជាទីឋាន "មេសូប៉ូតាមី" (Mesopo-

tamie) មួយផ្សេងទៀត ទីឋាននេះ ដីមានជីជាតិល្អវិសេសណាស់ មានប្រជាជនកុះករច្រើនបំផុត គឺមាន ២០០នាក់ក្នុងមួយគ.ម.២ ។ ទីឋាននោះហើយដែលជាមជ្ឈមណ្ឌលនៃជនជាតិសាសន៍ពីបូកណា ដែលមាននាមបញ្ញត្តិថា "សាយ៉ាំតែះ" ។ លុះហួសទៅដល់ទីក្រុងពារាណសីហើយ មាត់គង្គានេះ [illegible] ទទឹងពី ៨០០ម. ទៅ ២.០០០ម. តាមផ្លូវ ហើយទទួលពីខាងស្ដាំនូវស្ទឹងសោន (Son) ពីខាងឆ្វេងនូវស្ទឹងឃាគ្រា (Ghaghra) និងស្ទឹងគណ្ឌក (Gandak) ហើយមានទំហំកាន់តែធំឡើងៗទៀត ។ កម្លាំងទឹកខ្លាំងណាស់ [illegible] កម្ពស់ទឹកពី ១៤.០០០ម៣ ទៅ ១៦.០០០ម៣ គឺក្នុងកាលវេលាមហានទីព្រហ្មបុត្រដែលចេញមកពីប្រទេសទីបេតដូចគ្នា ក៏ហូរយ៉ាងលឿនតាមរដ្ឋអាសាម ហើយមកបង្គួបគ្នាជាមួយមហានទីគង្គានេះ កម្លាំងទឹកនេះខ្លាំងពីទី៤ ក្នុងពិភពលោក ។ ដីសណ្ដនៃមហានទីទាំងពីរ

នេះមានទំហំធំណាស់ ប្រមាណជា ៨០.០៤០គ.ម.២ ធំជាងដីសណ្តទន្លេនីល ដល់ទៅ ៣ ឬ ៤ ដង ជាដីសណ្តធំជាងគេបង្អស់ក្នុងពិភពលោក ។

គង្គាប្រទេស គង្គាប្រទេសជាទីវាលធំធេងដ៏ក្រៃលែង ការផ្លាស់ប្តូរកិច្ចការរ៉ូ ឬដំណើររឿង នៅទីនេះមិនឆាយខឹងគឹង ដល់គ្នាទៅវិញទៅមកបានទេ កិច្ចការសព្វគ្រប់តែងប្រព្រឹត្តទៅតាមតែទីវាលនេះរៀងខ្លួន ទៅតាមជម្រាលទឹកដី ទៅតាមអាកាសធាតុ ទៅតាមប្រមាណផង ។ សណ្ឋានភាគក៏ប្រព្រឹត្តទៅតាមទីហនដែរ ពីលើទៅក្រោម នេះតែងស្រុចទៅតាមផ្លូវទឹកបណា-ខទីនេះ តែទៅភាគក្រោម ទឹកនេះហៀរទៅច្រើនជាងទៅវិញ ។ ដូច្នេះ គេអាចកត់សំគាល់បានខ្លួនឯងភាគទឹកដីនៅចន្លោះទីហានដោអាពនិងអ៊ូដ (Doab-Oudh) ដែលនៅចន្លោះរដ្ឋឧត្តរ-ប្រទេសនិងរដ្ឋពិហាររួមទាំងមគធៈផង ។ រដ្ឋពេង្គលមានខ្យល់ច្រករនាមច្រើន តែដីសណ្តភាគក្រោមនេះជាដីលិចទឹក ។ ៦

រុក្ខជាតិ គេឃើញដើមឈើមានប្រភេទផ្សេងៗច្រើនដូចពួកសំបួរ (Acacia Sénégal) ដំបងយក្ស (Cactus) អម្ពិល (ហៅ.អម្ពី) ស្ដៅ (ample margousier, ហៅ.នីម) ចេះតែខ្សត់ទៅៗ នៅភាគក្រោមនេះ ហើយមានដើមស្វាយ, ដើមដូង, កុម្ពជាតិ, ដើមផ្ទៃទៅវិញៗ វប្បកម្ម មានធញ្ញជាតិប្លេ (Blé) មីល្លេត (Millet, ហៅ. ក្ងា, ពោក្រា) ដែលមានទៅខាងភាគលើ ឯខាងភាគក្រោមមិនសូវមានទេ មានច្រើនតែអំពៅ, ស្រូវ, គ្រទៅវិញៗ សត្វស្រុក ទុដមានតែភាគលើ ភាគក្រោមមិនសូវមាន មានត្រឹមវត្តពិហារ មនុស្សក៏មានចំនៀមទម្លាប់ផ្សេងៗគ្នាពាល់ដាប់ ដោយជាតិ ដោយភាសា ពាំងអស់ស្ទុតែងនៅៗចឹពីគ្នា ធម្មជាតិចឹកដីដែលផ្សេងៗគ្នាធ្វើឲ្យមនុស្សជាតិផ្សេងៗគ្នាដែរ គឺប្រព្រឹត្តទៅតាមភូមិភាគឧត្តរមហានទីគង្គា ដែលមានជាតិជីតណ្ហាន់, នៅភូមិភាគមហានទីនេះ, ត្រង់ភូមិភាគមាត់ជលមគ្គខាងទិសទក្សិណ ដែលមានតែជាតិជីថ្មហើយ

ហ៊ុំព័ទ្ធដោយបុប្ផាសព្វៗ ដែលជាបុរីទក្ខិណាបថ ៗ រួមទាំងទៅ
បានសេចក្តីថា ទឹកនេះខ្យល់ប្រែកខាប (វស្សរដូវ) ជាអ្នកឲ្យកើត-
ភាពកល់ឆ្នាំ, មាតាគង្គាទឹកសក្តិសិទ្ធិ ជាអ្នកជួយសង្គ្រោះ
ជាអ្នកផ្គត់ផ្គង់ជីវភាព គឺដោយមាតាគង្គានេះហើយដែលបាន
កើតភាយធំឥណ្ឌានេះឡើង ដូចជាទន្លេនីលដែរ មិនត្រូវមាន
ក្តីមោះមន្ទិលសង្ស័យឡើយ ៗ ឯទឹកហនក់លឥណ្ឌាទៀតសោត
ក៏ដូចទឹកវាលប្រទេសអេស៊ីបដែរ បើទឹកបានផលក៏ស្រេចហើយ
តែពីទឹកភ្លៀងនេះឯង ដែលពឹងតែសម្ពន្ធភាព ដែលមិនចេះទុនជួយ
ទៅវិញនេះ ក៏កើតមកតែពីមហាប្រពន្ធទាំង ២ ដ៏ធំខាងលើ
នេះ គឺមាតាគង្គា ១ វស្សរដូវ (ខ្យល់ប្រែកខាប) ១ ៗ តែ
ប្រទេសឥណ្ឌានេះ មិនមែនមានភ្លៀងធ្លាក់គ្រប់រដូវទេ ក្នុងមួយ
ឆ្នាំៗ មិនសូវមានភ្លៀងធ្លាក់ស្ទើរតែអស់ ៧ ខែទៅហើយ ម្ល៉ោះ
ហើយទេសភាពមើលទៅមុខគួរឲ្យស្រងេះស្រងោច ឃើញតែ
ធូលីដីសព្រោង ព្រឹក្សាលតាជាតិមិនមានពណ៌ខៀវស្រងាត់

ស្រស់បំព្រងនេះ មានអ្នកខ្លះក៏ស្រងាកចិត្ត ដោយប្មានឃើញភ្នំ
ភាគទិសពាយព្យនៃក្រុងកាលកត្តានេះ មិនមានអធិកភាពនៃ
ធម្មជាតិនិងព្រឹក្សជាតិញឹកញាប់ស្បាតរបស់ប្រទេសដែលនៅ
ក្រោមនិរក្ខរ៍នេះឯង ។

ទក្ខិណាបថ– តាំងពីហូគ្លី (Hugli) ទៅដល់ជ្រោយកោ-
មារិន (Kumàrin) ឆ្នេរសមុទ្រភូមិភាគនេះ មានដៃទូកាវ មាន
ខ្សាច់ច្រើនស្ទួកហូកហែង ៗ ទីជ្រាភាព ៣ យ៉ាងនេះ ត្រឹម
ត្រូវទៅតាមរបងសម្ពន្ធខ្ទួទៅនៃភូមិភាគទក្ខិណាបថនេះហើយ
ព្រោះជាខ្ពង់រាបប្រកបដោយជាតិថ្មផលិតដែលផ្សៀងពីរើតទៅ
ក្បៀសាន, មានកំពូលភ្នំខ្ពស់ ឆាកបែរទៅទក្សិណប្រមាណជា
២.៧០០ម. គេហៅខាងបស្ចិម មានជួរបព៌តជាឃាត (Ghat =
ជណ្ដើរ) ដែលលេចត្រដែតចេញពីសមុទ្រអារ៉ាប់ ៗ ជាយ
ឃាតម្ខាងទៀត ធំកលជ្រាលទាបល្ហម បែរទៅឈូងសមុទ្រ
បេង្គាល មានជួរភ្នំរដោចៗ ដែលគេចុកជាឃាតដែលបែរ

នៅខាងទិសបូព៌ ។ ភ្នំឃាតទាំងនេះហើយមានខ្នងជារនាំងបាំង ខ្យល់ព្រុកនោមមិនឲ្យបក់តម្រង់ទៅទិសឦសាន ហើយបែរជាឲ្យបក់ទៅទិសបស្ចិមវិញ បានជាភ្លៀងធំៗ មានច្រើនតែខាងទិសបស្ចិម ឯទិសផ្សេងៗ មានបន្តិចបន្តួចស្តួចស្តើងណាស់ ។

**ឆ្នេរកូរ៉ូម៉ង់ដែល**—*ភាគទិសបូព៌ ជាប់លេក្តៅអនេក ព្រោះនៅក្រោមកំណើតព្រះអាទិត្យ តែមានហេតុការណ៍ខ្លះនាំឲ្យស្រួលទៅវិញដែរ ។ ខ្យល់ព្រុកនោមមានសើមណាស់ មានតែក្នុងខែតុលា វិច្ឆិកា តែក្នុងកាលក៏មានភ្លៀងធំម្តងៗដែរ តែពោះបុច្ចម្កា យកជាការពុំសូវបានទេ ព្រោះតំបន់នេះតែងតែមិនសូវមានភ្លៀង បានជាតែងតែមានទុរភិក្សរាល់តែឆ្នាំនៅវឌ្ឍុវិស្សា ។ តួយ៉ាងខេត្តណាមួយនេះ សូម្បីមិនសូវមានភ្លៀងក៏ដោយ តែមានបរិកច្រើនហូរកាត់ដូចស្ទឹងមហានទី, គោតាវរី, ក្រឹស្នា, កាវេរីជាដើម ស្ទឹងទាំងនេះនាំពៅមកមិនបានទេ ដោយហេតុតែស្ទឹងវាដើមបរ៉ុមដោយច្ប៉ុ មានគ្នរ មាន*

ទឹកធ្លាក់ តែមានទឹកច្រើនបរិបូណ៌ ដីសណ្ដមានដីជាតិធ្វើស្រែ ចំការបាន ប្រជាជនក៏មានច្រើន ដូច្នេះ ឆ្នេរទិសបូព៌ ដែលបានឈ្មោះថា កោរ៉ូម៉ង់ដែល (Coromandel = coramandala = ចោរមណ្ឌល) និងសិរការ (Circars = Sarkàr) នេះ ជាដីសណ្ដមានដីជាតិធ្វើស្រែចំការបាន ។ ពួកកវីជាតិតាមិលបូរាណ ជាអ្នកចេះសង្កេតប្រសើរ ចេះភូមិសាស្ត្រប្រាកដ បានពណ៌នាទេសភាពភូមិភាគនេះទុកល្អ គួរឲ្យចាប់ចិត្ត ចាំថ្លែងថា . ស្ទឹងកាវេរីជាយន្តម៉ែយដ៏ល្អធើតធាយ ចិញ្ចឹមទាំងលទិសបូព៌ឲ្យមានជីវិតរស់ ដោយសារទឹកនៃវស្សរដូវ ដែលខ្លួនបានទទួលពីឃាតបស្ចិមនាំយកមកដាក់នៅទីនេះ ធ្វើឲ្យដីមានជីជាតិល្អ ៗ ដោយហេតុនេះ តំបន់តញ្ជោរ (Tanjore = Tanjàvùr = តញ្ជាវូរ) និងតំបន់ការិកាល (Kàrikal = Kareikal) ល្បីល្បាញថាជាទីឋានមានជីជាតិបំផុតគ្រប់រដូវ គេទុកជាដើមប្រមាក់នៃផលជាតិតាមិល ៗ សព្វថ្ងៃនេះ មាន

ទំនប់ទឹកដ៏សម្បើមនៅមេត្តូរ (Mettur) ។ កាត់មាត់សមុទ្រ មានកំពង់ធំច្រើន ឯកំពង់ពីបុរាណគឺ កំពង់ខាបេរិស (Khabèris = Kaverippattinam = កាវេរិប្បត្តិន័ម) នៃលោកប្តូ-ឡេមេ (Ptomlémée) និងកំពង់ កៃល (Cail.) គ. កាយ៉ល (Kayàl). "ក្រពាំង ឬ ស្រែអំបិល" របស់លោកមាកូ ប៉ូឡូ (Marco Polo) នោះ កប់ទឹកលិចបាត់ទៅហើយ ។

ឆ្នេរម៉ាលបារ–ឆ្នេរម៉ាលបារ ជាបដ្ដិកាដីតូចចង្អៀត មានតែបឹងបួ បាំងដោយជួរភ្នំដែលគេទុកជាឃាត (Ghat = ជណ្ដើរ) ដែរ ។ អាកាសធាតុក្ដៅមធ្យម ក្ដៅបែកអន្ទ ហើយទទឹកសើម ដោយភ្លៀងរលឹមជានិច្ច កើតឡើងពីស្រ-ដូវដែលមកពីច្រកពីរ ។ មានព្រៃព្រឹក្សាសម្បើមអស្ចារ្យ ដើមដូង, ស្លា, ដើមភាលជាតិ, កៅស៊ូ ចំរើនរុងរឿងណាស់ នៅតាមដំរេក្ខ ។ ក្រៅពីដំណាំម្រេច តែ កាហ្វេ មាន ព្រៃព្រឹក្សាខៀវស្រស់បំព្រង ដើមម៉ៃសាក់ ដើមពណ៌ស្វាយ

(Palissandre) ដើមបណ្ណគ្គជាតិ . (Fougères arborescentes) និងគុម្ពឫស្សីធំៗទៀត ៗ នៅខ្ពស់ មានសត្វសាហាវដូចខ្លា ជាដើម ៗ ឯខ្ពង់រាប ស្ងួតហួតហែងណាស់ ដូចតំបន់ទាំងឡាយ មានម៉ៃសួរ (Maisùr) ជាដើម ៗ ទីឋាននេះ មានដីរ៉ែច្រើនជាងគេ ៗ

ភាគឧត្តរទក្ខិណាបថ– គេទៅខាងភាគឧត្តរទៀត នៅតំបន់មង្គលួរ (Mangalùr) បត្តកាដីកែតែតូចៗ ស្ទើរតែមិនមាន, មានតែដុំថ្មរដិបរដុបគ្រប់ទីក ហើយគេទៅ ដល់ភូមិប្រទេសមារាថី (Marathi) និងតំបន់កោងកាន (Konkàn) ៗ នៅខាងឧត្តរភូមិប្រទេសមារាថី ឧទ្ទិន្នភាពប្រឹថពី មានច្រើនបែបណាស់ ដុយភ្នាស្រាវជ្រះពីភាពដែលមុខគួរឲ្យស្រងេះស្រងោចនៃភូមិភាគប្រទេសកណ្ដាលទៅ ដោយមានជ្រលងស្ទឹងតាប្តី (Tàpti) និងស្ទឹងនម៌ទា (Narmadà) រហូតទៅដល់ខ្ពង់រាបម៉ាល្វា (Màlyà) ទីនេះមានព្រៃភ្នំធំ ៗ មានស្បែររដូវ ព្យាកបក់យកក្នុងគិម្ហរដូវ មានបឹងធំ ៗ ដែលហៅថា គន្ក

(Port. tanque, lat. stagnum = "ទឹកដក់") ច្រើន សម្រាប់ តម្កល់ទឹកទុកៗ វិហារតាំងពីមាល្វា (Malva) ទៅទល់ ឧជ្ជេន (Ujjain) រីវាំងរស់នេះ ជាវិហារដែលកើតអក្សរសាស្ត្រ សំស្ក្រឹតចំរើនបំផុត ហេតុដល់ថ្នាក់ប្រណីតបគ្គាធំ ៗ នៅភាគ បស្ចិម ជាវិហារមានផ្លូវកប៉ាល់ទៅក្នុងប្រទេសគុជរាត (Gujrat), ភាគខ្ពង់រាបនៃភ្នំអារាវល្លា (Aravala = Aravalli) មិនទី កាលនោះផងនៃកប់រតនបូជា ឯភាគបូព៌ានៃភ្នំអារាវល្លា មាន ឈូបព៌ត ស្ថិតជាវិហារហាមខេត្ត មិនជាទីកើតកេតមិន ប្រកបដោយអនាម័យនៃរដ្ឋបច្ចិមប្រទេស ។

ឯវិហារនៃខ្ពង់រាបទក្ខិណាបថ ត្រង់ផ្នែកកណ្ដាលខ្ពង់រាប ដូចជាតំបន់ហៃដេរ៉ាបាត មិនទាន់ស្គាល់ ប៉ុន្តែជាវិហារខ្ពស់ បាន កំពស់ពី ៣០០ម. ទៅ ៩០០ម. ហើយជាទីខ្សត់ទឹកភ្លៀង ដីមាន សុទ្ធតែក្រួសក្រហម ក្រួសគ្រប់ពណ៌ តាំងតែពីក្រួសឆ្មាទៅ ដល់ក្រួសដុំធំ ៗ គេយកក្រួសទាំងនេះទៅធ្វើជាគ្រឿងទឹ-

សម្ភារៈសាងជាប្រាសាទពជង្គួន ឬសំណង់អ្វីផ្សេង ៗ ៗ ត្រង់ទីណាដែលមានទឹក ទីនោះ គេអាចធ្វើដំណាំបន្តិចបន្តួចបាន ឃើញពិសេសចំពោះតែភាគនិរតីតំបន់ម៉ៃសូរ ព្រោះមើលទៅឃើញទេសភាពស្រស់ញញឹមបំព្រង គួរជាទីជ្រះថ្លាគ្រាន់បើ ៗ នៅភូមិភាគម៉ៃសូរនេះ គេអាចសាងជាមហានគរដ៏ឆើតឆាយបាន ព្រោះនៅទីតាំង មានព្រៃព្រឹក្សា អាកាសធាតុត្រជាក់ល្មម ឯក្រួសគ្រប់ពុន បានជាគ្រឿងទ្រព្យសម្ភារៈដ៏សំខាន់ ដូចក្រុងពេង្គលូរ (Bengalùr) នេះ មានសួនច្បារល្អវិសេសណាស់ ទីហ្នឹងទុកជាចំណតយានយន្តក៏ល្អបំណាប់ ៗ កាលពីសម័យព្រេងនាយក្រុងពេង្គលូរនេះ ជាក្រុងវិជយនគរមានប្រជាជន ៤០០.០០០ នាក់ សីតុណ្ហភាពមានកំរិតពី ១៨ អង្សាទៅ ១៩ អង្សា, មានកំពស់ខ្ពស់ពីផ្ទៃសមុទ្រប្រមាណជា ៩២០ម. ។ ក្រុងពេង្គលូរដែលល្អឆើតឆាយនេះ គេទុកជាក្រុងគជពន្រាយនៃបូព៌ាប្រទេស (le perle de l'Orjent) ។

ធម្មជាតិទឹកដី នឹងហាក់ត្រូវនៃប្រទេសណា ដែលយើងបានសិក្សាមកនេះ ផងបរទេសគ្រប់គ្នា គ្រាន់តែជាន់ដីនេះហ៊ុំកតិជីងក្លាយជា ទឹកដីនេះពិតជារើងមែន រើងមិនទៅតាមមនុស្សដោយងាយទេ តែជនណាក៏ជាអ្នករើងមិនព្រមចាញ់ធម្មជាតិ ទំប្រឹងយកឈ្នះទាល់តែបាន ដោយប្រើវិរិយៈភាពជំរុះមុតស្វិតប៉ុន្មានឆ្នាំ កែទម្រង់ធម្មជាតិដ៏រឹងរូសនេះ ឲ្យចាលចាញ់គេដៃមនុស្សជាតិ ហើយធ្វើឲ្យកើតជាប្រយោជន៍ទីបំផុត បានសម្រេចផលសមតាមប្រាថ្នា គួរអស្ចារ្យនៅក្នុងចំពោះប្រវត្តិសាស្ត្រ គឺកាប់ឆ្ការរើព្រៃផ្សៃ ផ្លុំកាកាសធាតុ កនដីឲ្យក្លាយទៅជាស្រែចំការ សាងក្រុង សាងភូមិករគេហដ្ឋានប្រាសាទវិមាន ធ្វើទំនប់ទប់ទឹកបញ្ចូលស្រែចំការ បង្គមនាគមន៍ភ្ជាប់ខ្សែពេញប្រទេស ព្រមទាំងសានមនុស្សឲ្យមានចំណេះវិជ្ជា ដែលជាប្រភពនាំឲ្យកើតទ្រឹស្តីគ្រប់ជំពូក ល្បីល្បាញក្នុងពិភពលោក ប្រាកដដូចក្នុងបច្ចុប្បន្នកាលនេះ ។

ផងឥណ្ឌាតស៊ូយ៉ាងក្លាហានគ្រប់វិធីតាមដែលអាចធ្វើបាន មិនចំពោះតែឈប់ផាត់ទឹកដីប៉ុណ្ណឹងទេ តស៊ូចំពោះសត្វសាហាវយង់ឃ្នងទៀត តែគេមិនប្រើវិធីហិង្សាទេ គេហាក់ដូចជាពេះធ្វើឲ្យសត្វសាហាវទាំងនេះ មានវិចារណញាណទៅវិញ គឺពេះខ្ញាមដំរី ជាសត្វដែលមានរូបធំខ្សាំង យកប្រើធ្វើជាសត្វស្រុក ធ្វើជាពាហនៈបាន ពេះខ្ញានពស់ដែលមានពិសពោរពេញទៅឲ្យស្លាប់បង្ក្រាប់បះបរកំបាន ពេះរក្សាប្រើតបង្វើឲ្យទៅជាមួយមនុស្សពេលាកៈដោយគ្រប់គ្រាន់ខ្ពបាន មិនសូវពេះយកសត្វមកធ្វើជាអាហារបរិភោគទេ គ្រប់ទំហំនេះឃើញហ្វូងបក្សីដូចសេក សារិកា ក្អែក ៗ ល ៗ នៅជិតមនុស្សគ្រប់កាល ៗ

ក្នុងសម័យព្រេងនាយ គមនាគមន៍ចេញទៅប្រទេសក្រៅមិនសម្បូរណ៍ទេ ព្រោះផែនដីប្រទេសនេះមានបត់គង់ ៗ ជាកំពែងទៅព័ទ្ធជុំវិញ មានតែច្រកខ្វះ នៅចុងបត់គហិមាល័យខាងទិសបូព៌ទិសបស្ចិមប៉ុណ្ណោះ ៗ តាមច្រលងមហានទីព្រហ្មបុត្រ

មានច្រកតូចចង្អៀតមួយចេញចូល សម្រាប់ធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសចិន ។ នេះទុកជាគមនាគមន៍ដ៏បរិតហិមាល័យ ខាងទិសបូព៌ ។ តាមជ្រលងបព៌តការាករ៉ម មានច្រកមួយចេញចូលបាន តែមិនសូវសំខាន់ទេ ។ ច្រកមួយគ្រាន់បើបន្តិច គឺច្រកចេញចូលតាមប្រទេសអ៊ីរ៉ង់ ហៅថាច្រកបព៌តម៉ាក្រាន (Makràn) ជាច្រកដែលព្រះបាទអាឡិចសង់ឌ្រើមហាកដថយដៃ ហើយដកថយចេញទៅ ។ ច្រកមួយទៀតចេញពីតំបន់សេស្ថាន (Seisthàn) កាត់កន្ទហារ (Kandahàr) ទៅពោឡាន (Bolàn) ។ គេអាចទៅមកបានខ្លះដែរតាមជ្រលងស្ទឹងគុរ៉ម (Kurram) និងគោមល (Gomal) ប៉ុន្តែច្រកទាំងនេះ ច្រកដែលសំខាន់ជាងគេ គឺផ្លូវពីតំបន់កាប៊ូល (Kabul) តាមស្ទឹងកាប៊ូលទៅកាន់ច្រកខៃបារ (Khaibàr) ច្រកនេះហើយដែលព្រះបាទអាឡិចសង់ឌ្រើមហារាជ លើកទ័ពយាត្រាចូលលុកលុយយកប្រទេសឥណ្ឌា ។

នេះទុកជាគមនាគមន៍ចុងបព៌តហិមាល័យខាងទិសបស្ចិម ៗ

ឯគមនាគមន៍ក្នុងប្រទេស មិនមានឧបសគ្គធំដុំទេ សូម្បីឃាតបស្ចិមក៏មិនមែនជារនាំងធំដែរ គេអាចឆ្លងកាត់ទៅវិញទៅមកបាន ឯអារ្យធម៌ក៏ឆ្លងទៅមកតាមផ្លូវនេះដែរ ប្រែថាប្រទេសឥណ្ឌា មានឯកភាពខាងភូមិសាស្ត្រប្រសើរណាស់ រីឯកភាពខាងអារ្យធម៌ក៏ប្រសើរណាស់ដែរ ប៉ុន្តែគមនាគមន៍នេះ មិនត្រូវយល់ថាជាការងាយ ហើយទៅមកបានឆាប់តាន់ប៉ិត្តនោះទេ ៗ រីទីវាលឥណ្ឌូ-គង្គា ដែលឋិតនៅចន្លោះបព៌តហិមាល័យនិងវាលខ្សាច់ល្ហល្ហើរថារ (Thar) ក៏ជាច្រកចង្អៀត តែជាផ្លូវពាណិជ្ជកម្មក៏បាន ជាផ្លូវសត្រូវខាងក្រៅចូលមកក៏បាន តាមច្រកនេះហើយដែលកើតមហាសង្គ្រាមពីបុរាណកាលក្នុងប្រវត្តិសាស្ត្រឥណ្ឌា ដូចជារឿងមហាភារត-យុទ្ធនៅកុរុក្សេត្រជាដើម ៗ គមនាគមន៍នេះ មិនមែនមានធម្ម-ជាតិជាឧបសគ្គត្រឹមតែប៉ុណ្ណឹងទេ មានសត្រូវដទៃច្រើនទៀត

គឺទុរភិក្ស ពលទាហ៊ាន ព្រៃញាតស្វាត សត្វសាហាវ ទុរគមន៍ គ្រៀង ភក់ អាកាសធាតុ សត្វល្អិត ភយន្តរាយទាំងនេះ គួរស្សៀមណាស់ សូម្បីមេទ័ពហៅហានក៏ខ្ទប់ខ្លាច ញញើតរអាទ្រាំចញ្ញាប់ញ័រខ្លួនរលស់ព្យុះព្យាទា ព្រៃស្ងាត់ ទុរគមន៍ ទីផងមានតែចោរសាហាវយង់ឃ្នងនេះដែរ ។ នេះហើយដែលលោកហៅថា "មហាកន្ទារ" ជាឧបសគ្គធំបំផុតដល់បរទូតនៃកាយធម៌ បានជាអ្នកផងពោលទុកជាម៉ែវៀនថា "ព្រៃស្តុកបត់កន្ត្រៀនបត្យមប្រទេសនេះហើយ មិនមែនទុទ្ទិនភាពទឹកដីទេ ដែលញែកប្រទេសឥណ្ឌានេះជា ២ ផ្នែកឲ្យដាច់ចេញពីគ្នាគឺ ឥណ្ឌាអារ្យ័ននិងឥណ្ឌាទ្រាវិឌ" មហាកន្ទារនេះ មុខគួរឲ្យស្ញើនស្សៀមពិតប្រាកដមែន ។

កាលពីព្រេងនាយ ប្រទេសឥណ្ឌានេះ មានតែផ្លូវគម្នា យានជំនិះគម្នា ការធ្វើដំណើរ មានការលំបាកច្រើនណាស់ យានជំនិះបូកណាគឺរទេះគោ ប្រើគាងដាក់លើខ្នងគោ លា ទន្ធ

ជីរ ដំណើរទៅមកយឺតយូរណាស់ ដោយផ្លូវប្រទេសចំហួស ពេក ហើយគេបានពង្រាយមកសាងគមនាគមន៍ក្នុងប្រទេសឲ្យ ជាប់គ្នាអស់កាលយូរហើយ ដូចវិស័យផ្សេងៗឯទៀតដែរ គឺ ផ្លូវធំមួយចេញពីប្រទេសតានេះទៅរដ្ឋពេគ្គិល កាត់តាមបេសាវារ (Peshewar) និងបត្នា (Patna) បាប់កសាងតាំងពីរាជវង្ស មោរ្យៈ (Maurya) និងរាជវង្សគុប្ត (Gupta) ហើយគេបាន ឲ្យនាមបញ្ញត្តិថា "រាជមាគ៌ា" (Ràjmargà) ។ ផ្លូវនេះ មាន ដើមសាខានៅគង់កោសម្ពី (Kauçambi) ថែកទៅក្រុងឧជ្ជេន និងមហាក្រុង ។ រាជវង្សប៉ុនហ្គាលី (សេរសាហ៍ = Sér Sàh គ.ស.១៥៤០) បានជួសជុលផ្លូវនេះឡើងវិញ សព្វថ្ងៃនេះ មុខការគេនៃផ្លូវនេះ បិតបេះលុះមកដល់ឥឡូវ ហើយក្នុងកញ្ញ អង់គ្លេស គេបានរក្សាគមកទៀត ព្រមទាំងបានសាងផ្លូវរថ ភ្លើងមួយខ្សែធំ តាមបណ្តោយនេះហៅថាផ្លូវ "បញ្ចាប-មែល" (Punjab-mail) ពីក្រុងកាលកត្តាទៅបេសាវារទៀត ។ ក្នុងបច្ចុប្បន្ន

កាលនេះ ប្រទេសទាំងនេះបានធ្វើគមនាគមន៍នឹងឥណ្ឌា ឲ្យចម្រើនវិសេស ក្នុងសម័យព្រេងនាយឆ្ងាយណាស់ មានអយស្ម័យយាន រទេះសេះ យានយន្តគ្រប់ជំពូក ដែលជាមធ្យោបាយដ៏ប្រសើរនៃប្រជាជាតិមួយក្នុងលោក ។ ឯអយស្ម័យយានឥណ្ឌា បានរៀងដល់ថ្នាក់ទី ៣ ក្នុងលោក បន្ទាប់ពីប្រទេសអាមេរិកនិងរុស្ស៊ី ។

គមនាគមន៍តាមសមុទ្រ ផងឥណ្ឌាចេញទៅឆ្ងាយ តែមិនសូវចេញទៅទាន់បស្ចិមប្រទេសទេ ច្រើនទៅខាងបូព៌ាប្រទេស ទៅកោះលង្កា កោះជ្វា ដែលគេហៅថាសុវណ្ណទ្វីបនិងទៅសុវណ្ណភូមិ ក្នុងដែនប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ ។ ការធ្វើដំណើរក្នុងប្រទេសកាលនោះយឺតយូរណាស់ ចំពោះតែទៅមកដល់ចុងប៉ូចងកៀណាឡានៗ គឺពីរាមេស្វរ៍ (Ràmecyaram) ទៅឡាហ៍រ (Lahore) មួយឆ្នាំគត់ ទើបដល់ទៅវិញទៅមក តែបើតាមផ្លូវសមុទ្រចេញទៅប្រទេសក្រៅវិញ ដុំយគ្នាស្រួលៈ

មិនឃើញយូរពេកទេ ទៅកោះជាត្រីមៃកមួយខែ បើទៅប្រទេស
ខ្មែរសម័យអង្គរត្រឹមតែពីរបីខែ ទៅមកដល់គ្នាហើយ ។ នេះ
ជាហេតុការណ៍ដើមចមក្នុងប្រវត្តិសាស្ត្រនៃភាយធម៌ ។

និយាយដូចម្ដេចទៅឲ្យបានសមហ៎ះ?? នៅប្រទេសក៏ណា
នេះ មិនគឺប្រទេសដទៃទេ ដែលមនុស្សលោកសម្រេចចិត្តជា
ត្រូវតែតស៊ូចំពោះធម្មជាតិដ៏របស់នេះយកឈ្នះឲ្យបាន ។ ស្នាដៃ
ដ៏ធំហិមានេះ បើលទៅពាក់ដូចនាមនុស្សលោកបានធ្វើកតិ-
កាសញ្ញាជាមួយធម្មជាតិ គឺសន្ធិសញ្ញាមួយដែលមានលក្ខណៈ
កើតឡើងពីគំនេកើតកៃក្នុង ។ រឿបជាតិមហាភូតរូបគឺ ទឹកដីដី
សម្បើមអស្ចារ្យត្រាកដដូចេះ មិនមែនមិនធ្វើឲ្យមនុស្សលោក
ផុសគំនិតកើតប្រាជ្ញា ធ្វើមខសិការប៉ុនម៉ាត់ ព្រមទាំងធ្វើឲ្យ
កើតបរមាសញ្ញេតនា ដោយក្ដីមាន ដែលកើតពីមនុស្សជាតិ
ជាត្រូវយកជាញជ័យឲ្យពាល់តែបាន ចំពោះគេជាទុក្ខភាពមហា
ភូតរូបដ៏រឹងពោលគឺ ទឹក ដី ភ្លើងខ្យល់ ដែលមិនមានចំប៉ុត

និងប្រមាណមិនបាននេះទេ ប៉ុន្តែតែរូបមនុស្សមាឌតូចល្អិត កញ្ច្រឹកដូច្នេះ ៗ មហាគូតរូបបែបនេះ ជាអ្នកឲ្យកំណើតមេលទ្ធិ មេហាសនា មេទ្រឹស្តី មេនិកាន មេវិជ្ជា ល្បីល្បាញខ្ទរខ្ទារយូរទៅក្នុងពិភពលោក លើកប្រទេសនេះឲ្យមានកិត្តិនាមថា ជាប្រទេសជាឯកនានៃបេតាយ៍ធម៌ ៗ

ប្រទេសឥណ្ឌា មានទំហំដីប្រមាណ ៤.១៨០.០០០ គីឡូម៉ែត្រការេ មានភូមិ ៧០០.០០០ ភូមិ មានប្រជាជន ៤០០ លាននាក់ មានកុលសម្ព័ន្ធផ្សេងគ្នា មានភាសា ៨៤៥ ផ្សេងគ្នា អក្សរផ្សេងគ្នា ប្រទេសធំមានប្រជាជនច្រើនដល់ម្ល៉េះ ខ្ទរណាស់តែការទាក់ទងគ្នាកើតជាឧបសគ្គ នាំមិនឲ្យរួមគ្នាបានដោយប្រពៃ តែសេចក្តីពិត ជួយគ្នាទៅវិញ ប្រទេសឥណ្ឌាមានឯកភាពជាក់ស្តែងបំផុតគួរឲ្យកត់សំគាល់ ប៉ុន្តែតែក្រុងធំ ១ បិតទៅឆ្ងាយពីគ្នា តែភូមិ ទាំង ៧០០.០០០ នេះ បិតទៅជាប់គ្នា ដែលជាដើមចមនាំឲ្យមានឯកភាពខាង ជំនឿសាសនា ខាង

ទំនៀមទម្លាប់ ខាងពាក្យសម្ដីរួមគ្នា ដោយមិនបាច់ចាំមានឯក-ភាពខាងការរដ្ឋនិងខាងភាសាជាតិតែមួយរួមគ្នាឡើយ ជួយគ្នាស្រឡះពីហេតុការណ៍នៃប្រទេសចិន ដែលជាប្រទេសធំជួបគ្នាតែមានឯកភាពខាងរដ្ឋខាងអក្សរខាងកាលប្រវត្តិជារួមគ្នាៗ

ឯជនជាតិខ្មែរ ដែលធ្លាប់នៅប្រទេសកួច មានប្រជាជនតិច មានអាហារគោជនបរិបូណ៌ ទឹកដីស្តុក មិនកាចពេក មិនហើនពេក អាកាសធាតុល្មម មិនក្ដៅពេក មិនត្រជាក់ពេក បើចូលមកដល់ប្រទេសឥណ្ឌា ហើយមើលទៅឃើញទឹកដីធំល្វឹងល្វើយ មហានទីហូរខ្លាញ់ បត់តែហេមពាន្តធំមហិមា ខ្ពស់ស្កឹមស្កៃ កំពូលសន្សស្រដោយទឹកកក បត់តំរៀងខ្ពស់ត្រដូចត្រដឹមព្រៃញាតសង្រាគគុគ្គម កាលខ្សាច់ធំលេងមិនធំ មើលទៅដាច់កន្ទុយភ្នែក ឃើញតែមេឃ ត្រង់ធំៗ ដូចក្រុងកាលកត្តាក្រុងប៉ុប៉ៃយ មានប្រជាជនតាំងលានៗ កកស្រទាប់គ្នា ទៅតាំងហ្វូងមកតាំងហ្វូង អាកាសធាតុយោរយៅ ក្ដៅក៏ក្ដៅអនេក

អនន្ត ត្រជាក់ ក៏ត្រជាក់ស្រេប សត្វះបើត្រាទ់តែក្តៅត្រជាក់ក៏
មនុស្សស្លាប់ដែរ, មើលទៅដូចជាវង្វេងកណ្តាលអព្វាជីធំថប់
ដូចគេខ្យល់ផកដង្ហើមគ្មាន ដេកមិនលក់ចក់មិនរហើយ សុំមិន
បាន ប្រុះប្រាណមិនស្រណុក ទឹកទៅដល់ស្រុកខ្លួន ដែល
គូចហើយស្អាត សប្បុណ៌ មិនសូវមានភ័យបារម្ភពីធម្មជាតិ
ទឹកដីនប្រោមទៀយ ។

# អារ្យធម៌ខ្មែរ

## សេចក្តីផ្តើម

ក្នុងលោកនេះ ឬក្នុងលោកដទៃទៀត តែងមានធម្មជាតិ ៤ ប្រការដែលជាប់តពាក់ព័ន្ធគ្នា ដូចច្រវាក់មិនញែកចេញពីគ្នាពុំបាន ។ ធម្មជាតិ ៤ ប្រការនេះគឺ

- ការកើត
- ការចំរើនឡើង ឬ ឧត្តុង្គ
- ការឱនថយទៅវិញ
- ការរលត់សូន្យទៅវិញ ឬអត្ថង្គត

តាមផ្លូវប្រវត្តិសាស្ត្រ យើងឃើញថា ការប្រព្រឹត្តទៅនៃមនុស្សជាតិ រមែងតែមិនរួចពីគោល ៤ ប្រការនេះបានឡើយ

ពោលគឺ កើតឡើង ចំរើនឡើង ទ្រុឌថយទៅ រលត់សូន្យទៅ ជាទីបំផុត ៗ ការអស់នេះ តែងកើតមានជាប់រហូតមក ៗ ប្រជាជាតិណាមួយ ដែលបានទទួលគុណចំរើនរុងរឿង មានអំណាចធំពិសាល ដូចជាប្រទេសខ្មែរយើងសម័យមហានគរ ក៏រលត់សាបសូន្យទៅវិញក្នុងវេលានេះ ៗ

សេចក្ដីពិត ធម្មជាតិ ៤ នេះ ហើយគឺជាប់ទាក់ទងគ្នាជាលំដាប់ទៅ ទាំងជាហេតុផលនៃគ្នានឹងគ្នាក៏កើតកើតមានឡើយ ៗ មនុស្សយើងកើតមកហើយ ក៏ត្រូវចំរើនឡើង កាលបើចំរើនឡើងហើយ ក៏ត្រូវតែចាស់ទ្រុឌទ្រោមទៅវិញ ទីបំផុតក៏ត្រូវស្លាប់ តែការកើត ការចំរើនឡើង ការចាស់ជរា ទាំង ការស្លាប់ទៅវិញទាំងអស់នេះ សុទ្ធតែជាផលដែលមានជាប់គ្នា ទាំងជាអ្វីជាហេតុនៃអ្វីក៏ពុំខានគ្រប់គ្រូ ដូចជាជាការកើត ជាហេតុនៃការចាស់ជរា ហើយការចាស់ជរាជាហេតុនៃសេចក្ដីស្លាប់ ដូច្នេះគឺមិនត្រូវពិតប្រាកដដែរ ព្រោះ